កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា ទំនៀមទម្លាប់ អក្សរសាស្ត្រ ចោះកត្ត្ដន្ធ្ស
អំពីពុទ្ធសាសនបណ្ដិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ-ប៊ុត ក្រមការ
នៅពុទ្ធសាសនបណ្ដិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះវេទសាស្ត្រា . ស្ងួ - ហ្ការយ
ក្រុមដំនុំព្រះធ្លៃបំផិត នៅពុទ្ធសាសនបណ្ដិត្យ

មាតិកា

ផ្នែកអក្សរសាស្ត្រ		*ទំព័រ*
ពុទ្ធសាសនបណ្ដិត្យ	ដូនតារស់ពួកសាធុការឆ្នាំថ្មី	១
	សេចក្ដីផ្ញើនដំណឹងអំពីពុទ្ធសាសនបណ្ដិត្យ រៀងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៥០	២
លោក ភ័យ-ប៊ុត ក្រមការ	ប្ញាប់ទ្ធន្ធនកុមារ កុមារី	៥
ន្ត្រី ញ៉ុក-ថែង	ការងារដ៏ជាប្ដូយញ៉ាំងលោកឲ្យចំណេះ	១១
រ៉ូវ៉ាស្ត្ល ឈឹម-ណារ	រឿងក្មេងកំព្រា (រឿងនិទាន)	២៨
ង - សារ៉ាត		
ព្រ្ស ស្ងួងហ៊ីរញ្ញវ៉ាត្ត	រឿងព្រ្ចងកូមា	៣៩
មនា		
លោក ម៉ុញ-ឌ៉ាត្រ ( )	ពុទ្ធសាសនានិងការហ៊ីរសាសនា.....	៤៣
ហ្ជ្ជ ( ) ( ) ( )	ដំណឹងពុទ្ធសាសនាក្នុងនានាប្រទេស	៥២

ឆ្នាំទី ២២ — លេខ ១ ខែមករា ឆ្នាំ ១៩៥០ — ដំឡៃដារ ១ ឆ្នាំ ១០៥ រៀល ។

ជូនសព្ជសាធុការពរក្នុងឱកាសបូលធ្នាំប្ចី

១៩៥០

ធ្នាំមួយពាន់ប្រាំបួនរយហាសិបគត់
សូមរលត់ទុក្ខរលាយនូវសោកភ័យ
សូមព្រះប្រិយមហាក្សត្រិយ៍ក្សាន្ទព្រះទ័យ
ត្រងរាជ្យប្ជៃបានយូរកាលអនាគត ។
សូមរាជរដ្ឋាភិបាលជាតិទេមរា
បានសុទាប្រសើរក្រៃបង្រៃផុត
សូមរាស្ត្រខ្មែរកបស្ជស្ទីយរល់ធាប់ធុត
ស្រួលប្រាកដតាមរាសនាកាំកង់លោក ។

ពុទ្ធសាសនបណ្ឌិត្យ

សេចក្តីជូនដំណឹងអំពីពុទ្ធសាសនបណ្ឌិត្យ

រឿងទស្សនាវដ្ត៌កម្ពុជសុរិយា

សូមជំរាបជូនដំណឹងដល់បងប្អូនរួមជាតិទាំងឡាយ

កាលពីឆ្នាំ ១៩៤៩ ដែលកន្ធងមកនេះ ទស្សនាវដ្ត៌កម្ពុជសុរិយា មិនអាចចេញផ្សាយតាមកំណត់រៀងរាល់ខែនោះ ដោយហេតុរោងពុម្ពមានអក្សរតិចមិនគ្រប់គ្រាន់នឹងប្រើការបោះពុម្ពរឿងផ្សេង ៗ ទួទៅ ។ ប៉ុន្តែចូលមកក្នុងឆ្នាំ ១៩៥០ នេះ រោងពុម្ពព្រះរាជទ្រព្យបានទទួលអក្សរថ្មី ៗ មកទៀតជាចំនួនច្រើន ល្មមប្រើការបោះពុម្ពទួទៅបានសព្វគ្រប់ទើបយើងមានសេចក្តីសង្ឃឹមថា កម្ពុជសុរិយា សម្រាប់ឆ្នាំ ១៩៤៩ រោងពុម្ពបានខំប្រឹងប្រែងបោះពុម្ពទស្សនាវដ្ត៌នេះ ឲ្យបានគ្រប់ចំនួនដល់លេខ ១៦ នៅចុងខែ មករា ឬខែ កុម្ភៈឆ្នាំ ១៩៥០ នេះមិនខាន ហើយនឹងព្យាយាមបោះកម្ពុជសុរិយា ឆ្នាំ ១៩៥០ តទៅទៀត លែលកឲ្យបានទាន់ពេលវេលា គង់មិនយឺតយូរជូចឆ្នាំមុន ៗ នេះទេ អាចចេញផ្សាយតាមកំណត់រៀងរាល់ខែ (១ខែ ១សៀវភៅ) ។

ឯរឿងរ៉ាវដែលមានសារប្រយោជន៍ដល់បងប្អូនរួមជាតិ ទាំងខាងផ្នែកអក្សរសាស្ត្រ ទាំងខាងផ្នែកសាសនា ជូចមានកម្មវិធីដោយសង្ខេបតទៅនេះ ។

ផ្នែកអក្សរសាស្ត្រ

១ - អក្សរសាស្ត្រខ្មែរ (គោលចារកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងពាក្យកាព្យឃ្លោងចាស់ៗ ឬទំនើបថ្មីរបស់អ្នកនិពន្ធដែលមានកេរ្តឹ ឈ្មោះក្នុងសតវត្សរ៍ផ្សេងៗ)

២ - ព្រះរាជពង្សាវតារប្រទេសកម្ពុជា នៅមានបោះពុម្ពផ្សាយត ទៅទៀត ។

៣ - ប្រវត្តិសាស្ត្រសាកល (បើចប់ប្រវត្តិសាស្ត្រតណ្ឌៀហើយ នឹងបោះពុម្ពផ្សាយប្រវត្តិសាស្ត្ររបស់ជាតិជទៃៗ តទៅទៀត) ។

៤ - រឿងសាមកុក នៅតែបោះពុម្ពតៗ ទៅទៀត ត្រាតែចប់ ។

៥ - ភោគកុលកុមារ ពាក្យកាព្យរបស់អ្នកទកញ៉ា ព្រះឃ្លាំងនង នៅតែបោះពុម្ពផ្សាយតទៅទៀតត្រាតែចប់ ។

៦ - សុភាសិតផ្សេងៗ របស់នានាជាតិ ។

៧ - រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់ជាតិជទៃ ។

៨ - រឿងទំនៀមទម្លាប់ខ្មែរ របស់ក្រុមជំនុំទំនៀមទម្លាប់ ។ល ។

ផ្នែកសាសនា

១ - ជំណឹងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ។

២ - ធម្មទេសនា ដែលមានសារប្រយោជន៍ដល់ពុទ្ធសាសនិជន ទាំងឡាយ ។

៣- ប្រទិបទ្វីបអាស៊ីនៅតែហ្ការពុម្ពផ្សាយតទៅទៀតត្រាតែចប់ ។

៤ - សីលធម៌របស់ពុទ្ធសាសនា

៥ - ទឹងជ្រើសរើសប្រើរឿងព្រះសូត្រខ្លះ ក្នុងសុត្តន្តបិដក ដែលមានសារប្រយោជន៍ទាងផ្លូវប្រតិបត្តិរបស់ពុទ្ធសាសនិកជន ។ ល ។

ពុទ្ធសាសនបណ្ឌិត្យ សូមជំរាបបញ្ជាក់ថែមទៀតថា ការសាទឹងអក្សរផ្ទាល់ត្រឿងឧបករណ៍សំខាន់ៗបំផុតរបស់ជាតិក្នុងសម័យបច្ចុប្បន្ននេះ ។ ប្រទេសជាតិដែលចំរើនរុងរឿងឡើង ក្លាយទៅជាការប្រទេសក្នុងលោកសឹងមានមូលមកពីការសាទឹងអក្សរជាតិ ដែលទុកជាកូនសោសម្រាប់ទ្រាយកសេចក្តីចំរើនគ្រប់ផ្លូវតាមត្រូវការ ។

ហេតុនេះ ពុទ្ធសាសនបណ្ឌិត្យ សូមប្រកាសជូនដំណឹងដល់អស់លោក អ្នកទាំងឡាយ ដែលមានបំណងល្អ ចង់ពង្រីកនឹងជួយទំនុកបំរុងអក្សរសាស្ត្រខ្មែរឲ្យបានចំរើនលូតលាស់ឡើងទាន់សម័យ សូមធ្វើចុះឈ្មោះជាវិទ្យានារដ្ឋកម្ពុជសុរិយា នៃពុទ្ធសាសនបណ្ឌិត្យក្នុងពេលឆាប់ៗនេះ ។ ពុទ្ធសាសនបណ្ឌិត្យ សូមអរគុណអស់លោកទុកជាមុន ។

របៀបជាវ : ត្រូវធ្វើឈ្មោះ - ទីលំនៅ នឹងប្រាក់ទៅអគ្គលេខាធិការក្រុមពុទ្ធសាសនបណ្ឌិត្យ - ភ្នំពេញ ឯតម្លៃជាវប្រចាំឆ្នាំ ១៩៥០ នេះ ១ ឆ្នាំ ១៤៥ រៀល (នេះគិតតែតឹមថ្ងៃហ្ការពុម្ពប៉ុណ្ណោះ) ។

ពុទ្ធសាសនបណ្ឌិត្យ - ភ្នំពេញ ថ្ងៃ ២៣ ខែសីហា ១៩៦៩ ។

Adresse:
M. le Secrétaire Général de l'Institut Bouddhique
à Phnom-Penh

សេចក្តីរំឭកដាស់តឿនកុមារ - កុមារី

លោកហ៊យ - ប៊ុកក្រមការ រៀបរៀងជាពាក្យកាព្យ

ជាតិចំរើនដោយអក្សរសាស្ត្រ មានបទបែបល្បះតាមមាត្រា
សរសេរតាមជនជាតិខុសអក្ខរា ប្រើខាងភពការមេឃចុះអ័ព្ទ ៗ
ប្រែលោកភូមិភពស្រុកខេត្តខ័ណ្ឌ ប្រែខ្លួនគ្រប់គ្រាន់ក្បួនប្រាជ្ញ
ប្រែបញ្ញាប់វិទ្យាទាំងថ្ងៃយប់ ទើបប្រទេសជប់មហាសិរិល័យ ៗ
បណ្ឌិតបូរាណគ្រូអាចារ្យ មាសពេជ្ររបនាក្តីប្រពៃ
គ្រូគិតអប់រំជាតិនិស្ស័យ ឲ្យបានថ្លាថ្ងៃអនាគត ៗ
ព្យាយាមប្រមូលបណ្ឌិតប្រាជ្ញ, ខំយកស្លឹកបាចអវិជ្ជាពត់
សតវត្សរ៍ដប់ប្រាំបួនកត់ ធីរៈប្រវត្តិក្បួនសៀវភៅ ៗ
អក្សរសាស្ត្រអតីតលំបាកស្រាវ បូរាណខំជ្រាវមិនយល់ផ្លូវ
សម័យវ្ទនអន្ធរនៅ សិលាចារិកជ្រៅជ្រៀតមិនជ្រាប ៗ
ថែមមានសង្គ្រាមចលាចល កម្ពុជាសកលកង្វល់ជាប
ជាតិខ្មែរបានដល់ទុព្វលភាព អក្សរសាស្ត្រពបរកមិនយល់ ៗ
គ្រូគិតបកប្រែសៀវភៅរៀន បំណោះរបៀនក្រោមមណ្ឌល
វិទ្យាគ្រប់បែបលោកដំកល់ ដំកើងជាតិដល់ផលចំរើន ៗ
ខេមរប្រុសស្រីខំរៀនសូត្រ សោយអាហារល្អតលាស់ក្រើន
ដំរេះបេះបាំប្រាជ្ញដាស់តឿន នាំគ្នាត្រាច់ល្បឿនលានមន្ទិល ៗ

ពូជឧស្សាហ៍ស្វាងវៃសង់អាត្មាបាន ធ្វើជាតិកល្យាណជាងពូជខ្ជិល
ទាបថោកវង្សត្រកូលពាលខូចចិល ម្តេចកម្ពុជារំកិលទាន់សម័យ ។
មនុស្សម្នាក់ពុំអាចសម្រេចការ ត្រូវធ្វើសាមគ្គាពលប្រស្រ័យ
ប្រុសស្រីក្មេងចាស់ជួយវិនិច្ឆ័យ ទើបថ្នៃបានឈ្នះពីហីនជាតិ ។
ធម្មតាសិលាអាស្រ័យដែក ញែកភ្លើងបំបែកធ្វើចេញធាតុ
មនុស្សត្រូវពឹងមនុស្សប្រាជ្ញឧព៌ទ សប្បុរសជាខ្នាតទើបពាក់ខ្នង ។
គួរអប់រំកាព្យឃ្លោងបាទកវី បទបែបពេញទីភ្លឺស្វាងវៃសង
ពាក្យពេចន៍ឃ្លោងឃ្លានិពន្ធតែង ឲ្យចេញភ្លើងផ្សែងផ្សព្វលោកា ។
រុក្ខជាតិព្រឹក្សព្រៃកាប់មកភ្លាម កុំភ្លេចឈូសនាមចាំងបន្ទារ
គួសបន្ទាត់ដាប់កែតាមប្រាជ្ញា ធ្វើគ្រឿងទព្វសម្ភារគ្រឹះហាបាន ។
ព្យាយាមដំដែកសព្វទិស កើតជាងរចនាប៉ូវថៅថ្កាន
ប្រទេសថ្កើងប្រុសស្រីព្យាយាមប្រាណ ប្រឹងប្រែងយកឋានៈសោភ័ណ
ភព ។

គួរៀនវិទ្យាសាស្ត្រសម័យ កាយវិភាគប្រស្រ័យចិត្តប្រាជ្ញ
មនុស្សព្រឹក្សចិត្តសាស្ត្រចាកយប់ យោនជាតិប្រសប់ចម្រើនយស ។
យកសត្វភមរាជាឧបម័យ ធ្វើជាតិឲ្យថ្លៃសោភ័ណខ្ពស់
ជញ្ជាបយកកេសរគន្ធរស រុករកស្វែងស្វះធ្វើសំបុក ។
កុំត្រាប់កង្កែបគុម្ពឈូកនៅ ត្រាប់កន្ធង់ដៅផុតពីកលិយុគ
នៅឆ្ងាយហើរឈមជម្រង់មុខ មកក្រេបរសសុខបានសួស្តី ។

កុំត្រាប់មេអំបៅត្រាច់សប្បាយ　　មិនយល់ខ្ទឹមស្រាយធម៌វិន័យ
ត្រូវយកទទាបងនិស្ស័យ　　លលកបក្ខ័យផ្ទែលផុំទ្រុង ៗ
វិទ្យាសាស្ត្រអប់រំយូរកាល　　កបបេះក្តីប្រាលយល់ក្រៅក្នុង
រកឃ្នាបប្រាជ្ញាផុតលិចលង់　　ឡើងចាកភក់ផុងកើតប្រាជ្ញប្រាយ ៗ
ធម្មតាគ្រាប់ឈើក្នុងប្រថពី　　ចំរើរកវិញកកកាយ
យល់សែងសុរិយាក្លាពីនាយ　　ទើបផ្សាយដើមដងដុះដាលឡើង ៗ
ដើមដូងស្រូបយកទឹកល្អក្រោម　　ត្រាច់ដាក់ឈមត្រង់មិនព្រងើយ
ក្នុងរលាសាច់ផ្លែមិនខ្វាបនៀយ　　ប្រែទឹកផ្អែមហើយហូរត្រជាក់ ៗ
គ្រូរៀនប្រវត្តិសាស្ត្រខេមរា　　ឲ្យជាតិថ្លៃថ្លាប្រាជ្ញាស្ម័គ្រ
គោកធ្លកព្រះបោងចិនឡាថ្នាក់　　មហាភផព្រាហ្មណ៍ដាក់វង្សវ័ន្ទ ៗ
សម័យហ្វូណន់ស្តេចអង្គរ　　ប្រាសាទបវរល្អច្រើនថ្កាន
ពោរពាសពេញដែនដីទិព្វស្ថាន　　នានាប្រទេសបានបបួបវ៉ាប ៗ
ពូជតាត្រសក់ផ្អែមគួរផ្អូកទឹក　　កម្ពុជាគោកទឹកមហាអំណាច
មហាភផ•ដុង្គកំពេញអាច　　ចូលក្ស៊ីងមមាចនិន្ទាលក់ ៗ
ប្រវត្តិសាស្ត្រនាំស្នេហាជាតិ　　ព្យាយាមសង្វាតកុំងោកង៉ក់
ក្មេងចាស់សព្វរលៀនទៅមុខ　　ញាំងក្លាហានទុកមរដកកេរ្តិ៍ ៗ
បើបានជាបាបលោកុត្តរ　　បើស្វែងបុណ្យល្អនិព្វានេ
បើឡើងគិរកុំរិះរេ　　ព្យាយាមគ្មានត្រេកំពូលលើ ៗ

បើបានធ្វើស្រែប្រូតកាត់ស្រេច បើប្រើកលកិច្ចកុំស្អាក់ស្ទើរ
បើចង់ស្ទួយជាតិឲ្យចំរើន ដំណើរនឿយហត់ទុក្ខកុំគិត ៗ
បើចង់បានពេជ្រខំកកាយ បើចង់ក្តីសាយចូលងងឹត
បើចង់បានសុខឲ្យហាត់ចិត្ត សាមគ្គីមូលមិត្តជាតិផុតមារ ៗ
បើធ្វើកិច្ចការបរាជ័យ ប្រឹងទាំងជើងដៃរងទុក្ខា
ចាត់ធ្វើម្តងទៀតមនោក្លៀវក្លា គង់សម្រេចប្រាថ្នាប្រយោជន៍ធំ ៗ
ពូជជាក្លាហានអប់រំក្មេង ក្លាត័ន្ទតែងតែខំសំ
ចង់បានប្រាជ្ញាឲ្យខំជំ ញយៗប្រជុំផលញឹកញាប់ ៗ
គួររៀនបេះចាំលេខគនិត នព្វន្តគួរគិតយល់សព្វគ្រប់
បេះក្រែលបានគ្រាន់ប្រាជ្ញប្រសប់ ប្រសើរក្នុងភពគង់ផុតភ័យ ៗ
បូរាណពោលចារចាឯក ខាងលេខជាទោតាមញាណញៀយ
ក្មេងចូរស្វាធ្យាយស្អាងនិស្ស័យ ចាស់ហើយយប់ថ្ងៃកុំភ្លេចប្រាណ ៗ
បើចំណេះជាប់បេះបច្ចុប្បន្ន ផ្តិតបេះគយគន់កបប្រើនស្ពាន
បេះអនាគតតាមលំអាន ប្រាសមនុស្សឲ្យបានហានសប្បុរស ៗ
ប្រទេសមានបុត្របុរសនាំ ថែទាំទាល់ឃើញដល់ត្រើយកោះ
កោរកែប្រជាតិកោសគិតស្មោះ ទើបផ្ដោះផ្ដាស់សម័យលោកា ៗ
ធ្វើការត្រូវគ្រាប់អ្នកស្ទូចត្រី ត្រួតនុយប្រស្រ័យអប្បមាទា
ស្ទួងមើលស្ទាបគិតកលប្រាជ្ញ ស្រេចទាញមច្ឆាយកគាស្រ័យ ៗ

កុំឲ្យទុកចិត្តសត្វមនុស្សា លល្ងកលាតលាវិនិច្ឆ័យ
ចរិតមារយាទពាក្យបច្ច័យ ឲ្យយល់ថោកថ្ងៃពាលបណ្ឌិត ។
ត្បូរៀនភូមិសាស្ត្រកម្ពុជា ភាពជាតិអាត្មាវាជការតិត
ចំនួនមនុស្សឈ្មោះក្រុងពិនិត្យ សេដ្ឋកិច្ចប្រពឹត្តទំនៀមស្រុក ។
ជាតិទ្មេរមិនស្គាល់កម្ពុជា ស្វាធ្យាយសាសនាតាមទំនុក
មិនដឹងពុទ្ធប្រវត្តិពូជកុក មិនស្គាល់បឹងថ្ងុកទ្រនំខ្ជូន ។
ស្គាល់ខ្ជូនៗ ឯងលំបាកផុត ស្គាល់ជទៃពុតទ្មេរចិនយួន
ស្គាល់ភពលោកមេយភាពច្បាប់ក្ស្ជូន ស្គាល់លោកធមិសួនលំបាកប្ងែក ។
ត្បូរៀនចងចាំប្រាជ្ញមេធី ឲ្យស្គាល់ពេញទ៉ីមនុស្សសត្វញែក
តក្តវិទ្យាស្វាធ្យាយសែក សេពសំទតមែកដើមបុសតល់ ។
ធ្ងល់សង្ស័យនាំមានប្រាជ្ញា បើបានជាថាឲ្យមានផល
បើបានជាដើរទំឲ្យជល់ បើបានជាជល់កុំខ្ជាចស្ជាប់ ។
ឈស្សាហ៍ព្យាយាមទើបបានចេះ ចង់ចេះធលាជាំប្រាវត្ត
ហេតុមនុស្សសត្វងងិតយប់ បចមកល្ជត្រប់ស្គាប់មិនពុ ។
កលោកទឹកដីត្រៃពឹក្សា កជាតិសាសនាយល់ស្ជាក់ស្ជើរ
បើមានបាវព្រាវឲ្យចេះប្រើ ប្រាជ្ញាជំណើរនាមរូបធាតុ ។
បញ្ចាក្ខន្ធបំបែកញែកតាមការ ឲ្យស្គាល់រូបនាមាតាមក្ស្ជូនខ្មាត
ចក្រវាឡតូចធំទំសង្ខាត លោកធាតុឈរាទឲ្យយល់ស្ត្រេង ។

គួរវៀនវិទ្យាហោរាសាស្ត្រ　　តារាធ្វៀតធ្លុះទ្រាំប្រឹងប្រែង
ស្គាល់ចរិតចរិយាផលកើតផ្សេង　　ដើមយផ្ទាយសំដែងរាស៍ចន្ទ្រ ។
ចូរប្រុសស្រីដែនកម្ពុជា　　ស្រឡាញ់គ្រប់គ្នាវិទ្យាគ្រាន់
លោកធម៌និស្ស័យឲ្យបានទាន់　　សម័យលោកកាន់ភ្ជាប់ចេស្តា ។
ទើបហៅស្រឡាញ់មាតុភូមិ　　សាមគ្គីព្រៀងព្រមស្ទាងវិទ្យា
ស្រឡាញ់ជាតិទឹកដីព្រៃ ព្រឹក្ស　　ស្រឡាញ់ពុទ្ធសាសនាបានថ្លាថ្ម ។
វិទ្យាជាប្រទីបផ្ទុះប្ចាជ្ញា　　ធ្វើជនខ្មែរកាន់ក្តីងយប់ថ្ម
វិទ្យាកបគុណល្អប្រពៃ　　ប្ចាជ្ញបណ្ណិតចរណៃដំកើងជាតិ ។
នារីតន់ប្ចុសអាជានេយ្ស　　ដឹកនាំប្រស័ យខ្មែរធ្វៀតធ្ងាត
ទើបធ្ងុះសរីត្រកូលញ្ញាតិ　　ស្ងួស្ត្តីលោកជាតុល្ស៍អស្ចារ្ស ។
វិទ្យាជាបិតារចនាគ្រប់　　រដ្ឋាភិបាលសព្ទតាមហ៊ានា
សង្ក្ត ម ផ្ទុះផ្ទាល់រៀបរាជការ　　ន ដ យ ប ាយ ខ្ម ែ ម ាកចំ ណ ែ ន ស ុ ខ ។
កែប្រែខ្មែរឲ្យទាន់កាល　　មានរស្ម៍ភ្ជ ីប្ចាលធ្ងុតព ីទ ុ ក្ខ
កែទឹកដីសាសនាតាមទំនុក　　ជាតិចញ្ចាកកក់ពស ុ ីវ ិ ល ័ យ ។
កែមតិទ ិ ដ្ឋ ិ ជ ន ជ ាតិ ប ាន　　កែ ច រ ិ យ ា ណ ា ន ត ្ រ ាច ់ យ ប ់ ថ ្ម
ចំ ណ ែ ន ស ោ ភ ័ ណ ធ ្ ង ន ់ ផ ្ ទ ា ល ់ យ　　ន ា ក ់ ス ុ ว ณ ្ ณ ដ ័ យ ផ ្ ទ ា ល ់ ត ្ ร ីយ ត ្ ร ាន ។
ក ន ់ ล ោ ก ว ิ ล ส ព ្ ท (ค ป ่ ท ิ ก　　ជ ន ជ ាតិ ข ม ก า ว ิ ล (ค ป ่ ป ุ า ณ
ប្រឹងប្រែងព្យាយាមកុំអាក់ខាន　　ផ ្ ទ ា ล ់ ส ្ ว ា ន ข ก ก ส ว ป ร ช า ธ ิ ป ไ ต ย ย ว ม ย ื น ។

ការងារជាមធ្យោបាយកាត់ផ្តាច់ចំណេះ

ហ្ស៊ីនិតន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

មនុស្សយើងដែលកើតមកក្នុងលោកគ្រប់រូប ត្រូវតែធ្វើការងារ ដើម្បីចិញ្ចឹមជីវិតរៀងខ្លួន, យើងអាស្រ័យនៅក្នុងលោក មិនធ្វើកិច្ចការអ្វីមិនបានជាដាច់ខាត ព្រោះកិច្ចការរបស់មនុស្ស បានក្លាយជាតួចក្រកម្លាំងយ៉ាងធំសម្បើមអស្ចារ្យ ដែលអាចធ្វើឲ្យមនុស្សលោកលែងមានសេចក្ដីចំណេះ ឥតអាក់ខានចាប់តាំងពីសម័យបុរាណ ជាបន្តបន្ទាប់ដល់សម័យបច្ចុប្បន្ន ។ មនុស្សសម័យបុរាណបានចាប់ផ្តើមធ្វើការតៗ គ្នាមកហើយ ចាប់យកចាប់ពាន់ឆ្នាំ ទើបលោកយើងបានជុះជាលចំណេះដូចសម័យសព្វថ្ងៃនេះ ។

តាមដោយពិតកិច្ចការ ស្នាដៃរបស់មនុស្សទេតើ ដែលជាតួចក្រយ៉ាងសំខាន់ សម្រាប់ឯកជន ក្រុមហ៊ុន ក្រុមសង្គម ក្រុមសម្រាប់ប្រទេសជាតិ រហូតដល់ពិភពលោកទាំងមូល ដែលយើងអាស្រ័យនៅសព្វថ្ងៃនេះ ។ ហេតុនេះ ទើបយើងមើលឃើញជាក់ច្បាស់ថា ក្នុងលោកនេះ គ្មានមនុស្សនៅចំនេះរេ សុទ្ធតែមានការងារទៅតាមសភាពរៀងៗ ខ្លួន កាលយើងនៅតូចយើងក៏ធ្វើការផ្សេង ។ មានស៊ីផឹក, ដេក, ដើរ, ឈរ, អង្គុយ, យំ, ស្រែក ។ល។ ដល់ចំណេះវ័យធំបន្តិចឡើង យើងក៏ធ្វើការសិក្សារៀនសូត្រ ហាត់លោត, ហាត់ត្រាំ, ហាត់ហែលទឹក ។ល។ ដល់

មានអាយុគ្រប់នីតិភាព យើងត្រូវធ្វើការងារចិញ្ចឹមជីវិតអាត្មានឹងគ្រួសារ ទៅទៀត ។ ការធ្វើរបរចិញ្ចឹមជីវិតនឹងការគ្រប់គ្រងរក្សាគ្រួសារ ជាការ: ប្រចាំរបស់មនុស្សគ្រប់រូបដោយពិត ។

ខ្ជួរក្បាលនឹងសេចក្ដីឈ្លាសវៃ ព្រមទាំងសេចក្ដីព្យាយាមរបស់មនុស្ស ទេតើ ដែលធ្វើឲ្យពិភពលោកដ៏ធំធូលាយមហិមានេះ សមជាទីស្នាក់នៅ នៃមនុស្សលោក ។ សេចក្ដីចំរើនដែលហៅថា អារ្យធម៌របស់លោកជា ផលដែលបានមកពីខ្ជួរក្បាលនឹងសេចក្ដីប្រឹងប្រែងធ្វើការរបស់មនុស្សទាំង អស់ ។ គ្រប់យ៉ាងក្នុងលោក តែងតែមានការប្រែប្រួលជានិច្ចគ្រប់ ១ នាទី ។ មនុស្សសម័យបុរាណ មានគំនិតចង់ហោះហើរដើរធ្យានលើ រ៉ូហ្ស៊ីដូចជាបក្សី ។ មានគំនិតគិតចង់បង្កើតយានជំនិះវិសេសផ្សេង ១ មកហើយ ដូចមានសេចក្ដីដំណាលពីមនោភាពរបស់មនុស្ស ក្នុងសាស្ត្រ ស្ទ្ធាវ្ស្ដ្ធនានា មានរឿងហត្ថាយន្ត ឬកូនម៉ាស៊ីយជាដើម ។

គំនិតគិតស្នានរបស់មនុស្សសម័យជាន់ដើម ក្លាយទៅជាការពិតឡើង ក្នុងសម័យជាន់ក្រោយនេះ ដូចជាយានជំនិះយ៉ាងវិសេស ១ ទាំងខាង ដើងទឹក ទាំងខាងដើងគោក ទាំងខាងអាកាស ដូចរថយន្ត, រថភ្លើង, ឡាន, យន្តហោះ សម្រាប់ពង្រីកផ្លូវគមនាគមន៍ឲ្យទូលំ ទូលាយ អាចទៅបានគ្រប់ទិសទីក្នុងលោក ។ ទាងការជួនដំណឹងគ្នាទៅវិញទៅមក ហាក់ ដូចជាយើងបានសម្រេចវិជ្ជាកែកទ្ធ ត្រចៀកទ្ធ ខាងចិត្ត ដូចជ្ជ្ជ្ជ

លេខនឹងវិទ្យាដើម ៗ ផ្នែកខាងការកែកពយកំសាន្តចិត្តក្នុងវេលាព្រើវិញក៏មានភាពយន្ត (កុនស្រមោល) នឹងវិទ្យុភាពយន្ត ហើយមកក្នុងសម័យបរមាណូនេះ វិជ្ជាការរបស់មនុស្សរឹងរឹតតែចំឡែកអស្ចារ្យណាស់ទៅទៀត ដូចជាគ្រាប់បែកបរមាណូនឹងវត្ថុសព្វសារពើ ដែលធ្វើពីធាតុបរមាណូ សុទ្ធសឹងតែអស្ចារ្យណាស់ ៗ ហើយអំណើះតទៅខាងមុខទៀត អាចកើតរបស់អស្ចារ្យចំឡែកថ្លែកៗ ថ្មីៗទៀត ច្រើនលើសលប់គណនា ដែលសម្រេចដោយបញ្ញានឹងស្នាដៃរបស់មនុស្សមិនខាន ៗ

ក្នុងចំណោមពួកអ្នកជញ្ជឹងរំពឹងគិតចង់រៀបចំ ពិភពលោកឲ្យបានចំរើនរុងរឿង ប្រកបដោយសេចក្តីសុខក្សេមក្សាន្ត បើពោលដោយភាគច្រើន គឺពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ ដែលបានខំប្រឹងកសាងសេចក្តីចំរើននឹងការស្រួលសប្បាយ ដល់មនុស្សជាតិផងគ្នា ៗ មានចួនកាល លោកអ្នកនឹកស្មានថា គំនិតពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ ជាគំនិតត់តហេតុផលហួសវិស័យមនុស្សលោក តមកសម័យខាងក្រោយ ក្លាយទៅជាការពិតជាក់ស្តែងឡើង ពិភពលោកទើបប្រជាប់ប្រជាដោយរបស់ចំឡែក ៗ ច្រើនជាអនេកប្រការ គួរឲ្យអស្ចារ្យណាស់ ដែលជាផលកើតឡើងដោយសតិបញ្ញា នឹងស្នាដៃរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រដោយភាគច្រើនបំផុត ៗ

កាលបើយើងសំឡឹងមើលជុំវិញខ្លួនយើង ហើយសួរខ្លួនឯងថា នរ-ណាជាអ្នកកសាងវត្ថុផ្សេង ៗ អស់ទាំងនុះឡើង អ្នកណាកសាងរថយន្ត, រថក្រើង, ក្រើងអគ្គិសនី, យន្តហោះជាដើម អ្នកណាជាអ្នកគិតផ្សំថ្នាំបំបាត់រោគនានា ; អ្នកណាជាអ្នកគិតប្រឌិតផលិតភ័ណ្ឌ អំពីវត្ថុឥតជំឡៃនានា ឲ្យទៅជារបស់មានប្រយោជន៍ ត្រាតែយើងមានគ្រឿងប្រើប្រាស់ប្រៃក ៗ ច្រើនជាអនេកអនន្ត ; យើងអាចតបដោយខ្លួនឯងថា ពួកអ្នកប្រាជ្ញវិទ្យា-សាស្ត្រអស់នោះហើយដែលបានប្រសិទ្ធ៍ និរមិត្តវត្ថុអស់នោះឲ្យកើតឡើង ៗ អ្នកប្រាជ្ញវិទ្យាសាស្ត្រទាំងឡាយ មិនបានប្រាថ្នាផលប្រយោជន៍ផ្ទាល់ខ្លួនប៉ុន្នានទេ ដោយយល់ឃើញហើយប្រកាន់ថា កាលបើកើតមកជាមនុស្ស ត្រូវតែបំពេញមុខក្រសួងរបស់មនុស្សគឺជួយគ្នាពួតដៃគ្នាគ្រប់គ្រងពិភពលោកឲ្យបានចំរើន ប្រកបដោយបកតិសុខយ៉ាងធំទូលាយ ៗ ដោយហេតុពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ មានបំណងចំពោះផលចំរើនដោយរួបរួមគ្នានេះ ទើបយើងគួរចារិករំលឹកគុណ របស់បុគ្គលដែលធ្វើសារប្រយោជន៍ដល់លោកគ្រប់ខណ: ៗ

ផលសម្រេច ដែលជួយសួយមនុស្ស ឲ្យមានកេរ្តឹ៍ឈ្មោះនឹងកិត្តិយសល្បីល្បាញ ព្រមទាំងធ្វើឲ្យប្រទេសជាតិចំរើនរុងរឿងឡើង នេះនាំឲ្យយើងយល់ថា ផលសម្រេចជារបស់សំខាន់ក្រៃលែង ប៉ុន្តែការដែលនឹងញ៉ាំងផលសម្រេចរបស់ខ្លួន ឲ្យបានដល់គោលបំណងនោះ លុះតែ

អាស្រ័យសមត្ថភាពក្នុងការងារជាគោលសំខាន់ ។ ផ្លូវសាលារៀន អ្នកប្រាជ្ញវិទ្យាសាស្ត្រកាលគ្នានឹងពួកអ្នកសិល្បៈ ចានទំព្យាយាមយ៉ាងម៉ឹងម៉ាត់ ដើម្បីញ៉ាំងការដែលខ្លួនធ្វើនោះ ឲ្យចានសម្រេចជារូបរាងឡើង ។

តាមធម្មតា មនុស្សយើងមានអំណាចមួយ ដែលធម្មជាតិចានប្រគល់ឲ្យមក គាំងពីកំណើត គឺខួរក្បាល ។ មនុស្សដែលមានខួរក្បាលរមែងមានសតិបញ្ញាសម្រាប់ត្រិះរិះរកហេតុផល ចំពោះរបស់ដែលមាននៅជុំវិញខ្លួនយើង ត្រមទាំងគោលការសម្រាប់ពិចារណាព្រឹត្តិការណ៍ចានជាក់ច្បាស់ ; ដំណើរនេះធ្វើឲ្យមនុស្សជាតិ មានការ:ខ្ពង់ខ្ពស់ជាងសត្វសត្វទាំងឡាយយ៉ាងត្រដែតត្រដឹម ។ ផលសម្រេចគ្រប់ចំណែកដែលមាននៅក្នុងលោកនេះ កើតមកអំពីស្នាដៃរបស់មនុស្សទាំងអស់ ចំណែកខាងសត្វសត្វទាំងឡាយ គ្រាន់តែជាគ្ងីដ ឬជាគ្រឿងឧបករណ៍មួយយ៉ាង ដែលមនុស្សប្រើប្រាស់ ឈ្លាសវៃរបស់ខ្លួន យកមកបង្ហាត់ប្រើការជាប្រយោជន៍ដល់មនុស្សផងគ្នា ។ មនុស្សជាតិនេះជាអ្នកគ្រប់គ្រងពិភពលោកមកហើយកាប់ស្ទានកាប់ឈានធ្នាំ ហើយនឹងតាំងនៅក្នុងលោកផ្ទាល់លោកបែកឆ្ងាយទំលាយទៅវិញ ។ ការបើយើងដឹងថា មនុស្សជាតិត្រូវចានគ្រប់គ្រងលោកដូច្នេះ ទើបត្រូវតែយើងដែលជាមនុស្សគ្រប់ ១ រូប ប្រើសមត្ថភាពក្នុងការគ្រប់គ្រងលោក ដោយការធ្វើឲ្យកើតសន្ដិសុខ ត្រមទាំងអារ្យធម៌ថ្លៃថ្នូរដល់លោក ចានដល់ការធ្វើខ្លួនឲ្យមានប្រយោជន៍ដល់លោករួបរួមគ្នា ។

សេចក្ដីសម្រេចគ្រប់យ៉ាង កើតមកពីគំនិតមានបំណងមុតមាំ ជា
មូលដ្ឋានដ៏សំខាន់ ៗ កាលពីមួយរយឆ្នាំមុននេះ ឬមុននោះឡើងទៅ
ទៀត គ្មាននរណាគិតនឹកថា មនុស្សយើងអាចហោះហើរបាន ឬមានយន្ត
ហោះអណ្ដែតលឿនទៅក្នុងនភាកាសបាន ជាយានយ៉ាងវិសេស មាន
សន្ទុះលឿនស្មើគួរឲ្យអស្ចារ្យ ជាការពង្រួញផ្លូវគមនាគមន៍យ៉ាងឆ្ងាយ
ណាស់ ដែលពីដើមត្រូវធ្វើដំណើររាប់ខែឬឆ្នាំទើបទៅដល់ ឥឡូវនៅ
ត្រឹមតែរាប់ម៉ោងឬរាប់ថ្ងៃប៉ុណ្ណោះ ៗ ក្នុងទឹកមានកប៉ាល់កាណូតជាដើម
ប្រើជាយានយ៉ាងលឿនស្មើមិនបាច់ប្រើចែវប្រា ប៉ោលឬក្ដោង ៗ លើ
គោក មានរថយន្ត រថភ្លើង ប្រើបានរហ័សស្រួលសប្បាយជាអនេក ជា
ជំនួសរទេះសេះ ឬរទេះគោ ឬដំរី ៗ ក្រៅអំពីនេះនៅមានគ្រឿង
ឧស្សាហកម្មផ្សេងៗទៀត ដូចជាឧស្សាហកម្មតម្បាញការដេរប៉ាក់
ដោយយន្ត ពួកអ្នកគិតប្រឌិតវត្ថុអស់នេះដំបូងបំផុតនោះ ត្រូវនាំគ្នាសើច
ចំអកឡកឡឺយ ហើយយល់ថា ជាគំនិតឆ្កួតរវើរវាយឥតខ្លឹមសារ ៗ
ដរាបដល់ពួកអ្នកដែលធ្វើគ្រឿងភាជនដីដុត ដែលយើងប្រើប្រាស់សព្វថ្ងៃ
នេះ ក៏ត្រូវគេចោទបរិហារថាឆ្កួតផ្ដេសផ្ដាស ឬថាល្ងង់ល្ងឹតណាស់ ៗ
ប៉ុន្តែអ្នកដែលមានគំនិតដែលគិតប្រឌិត បានខំព្យាយាមរកវិធីធ្វើគ្រឿង
ភាជនដី (ពែង, ចាន, កន្ធោរ,) ត្រាតែបានសម្រេចដូចបំណងនោះ
គោងចាយរាយទ្រព្យសម្បត្តិស្ទើរតែអស់លើងពីខ្លួន ហើយអស់ពេល

រៀលាស្រាវជ្រាវរកដល់ ១០ ឆ្នាំ ទើបបានសម្រេច ដូច្នេះទើបយើញថា អ្នកដើមគំនិតដែលបានគិតប្រឌិតរបស់ប្ចែក ៗ ទ្បើង ជាមនុស្សមានគំនិតមុតមាំ មានព្យាយាមមឺងម៉ាត់ណាស់ ។

ចិត្តិទ្ធិបាទជារបស់សំខាន់បំផុត ដែលអាចញ្ចាំងសេចក្តីសម្រេចឲ្យបង្ក្រើតទ្បើងបានដល់មនុស្សគ្រប់រូប ។ អ្នកធំ ៗ ប្ចរដ្ឋបុរស ត្រូវតែមានបំណងមុតមាំជាប្រធាន ទើបបិតនៅក្នុងតំណែងសំខាន់ ៗ បាន ដោយបង្ហាញឲ្យយើញសមត្ថភាពក្នុងការងារ ហើយអាស្រ័យសេចក្តីព្យាយាមមិនរួញរា ត្រាតែបានទៅដល់ផលដែលខ្ជួនប៉ុនប៉ងសំដៅទុក ទើបយើញថា សេចក្តីសម្រេចត្រូវអាស្រ័យហេតុ ២ ប្រការ គឺបំណងនឹងសេចក្តីព្យាយាម ហើខ្ចះគុណធម៌ ២ ប្រការនេះ រមែងនឹងសម្រេចទៅបានដោយកម្រណាស់ ។ យើងគង់បានយើញស្រាប់ហើយថា ហាងរានលក់ដូរប្ចក្រុមហ៊ុន ដែលលើកលែងធ្វើការជំនួញ ព្រោះខាតទុន ប្ចលក់ដូរមិនដាច់ ។ ការដែលម្ចាស់ហាងរាន ប្ចអ្នកចាត់ការមិនមានបំណងនឹងសេចក្តីព្យាយាមមុតមាំ ក្នុងការលក់ដូរឲ្យបានចំរើនរុងរឿងត ៗ ទៅ មិនយកចិត្តទុកដាក់នឹងការទទួលបំរើប្រជាជន ដោយសុចរិតស្មោះត្រង់ទេ កិច្ចការខាងផ្ទូវជំនួញ . ក៏នឹងចំរើនលូតលាស់ទៅពុំបានដែរ ។

ការមានមានះមុតមាំនឹងសេចក្តីព្យាយាមមិនរួញរា ជាបច្ច័យយ៉ាងសំខាន់ក្នុងកិច្ចប្រកបការងារដែលខ្ជួនចាប់ផ្តើមធ្វើទ្បើង ឲ្យបានសម្រេចដូចបំណង ។

មានមនុស្សជាច្រើន ដែលនឹកចង់ផ្តើមធ្វើអ្វីក៏ចាប់ធ្វើការនោះ ទៅ តែគ្រាន់តែធ្វើទៅបានបន្តិច ក៏ធ្វើយណាយ រសាយ សេចក្តីព្យាយាមបន្តិចម្តង ។ គ្រាតែលែងធ្វើការដែលចាប់ផ្តើមធ្វើពីដំបូងនោះ ។ នេះបញ្ជាក់ឲ្យឃើញថា គេខ្វះសេចក្តីមានៈ ដែលជាដើមហេតុនៃសេចក្តីសម្រេចនុ៎ះឯង ។ គ្រាលសំខាន់ដែលនឹងធ្វើការឲ្យសម្រេចទៅបាននោះ ទៅត្រង់សេចក្តីមានៈព្យាយាមមិនរួញរា យកជ័យជំនះចំពោះឧបសគ្គនានាប្រការ ចុះដៃធ្វើរៀង ។ ទៅមិនអាក់ខាន មុខជានឹងបានទទួលផលសម្រេចជាប្រាកដ ។ មានជនគាំងចិត្តធ្វើការមុតមាំក្នុងជាន់ដំបូង ដល់ចាប់ធ្វើការនោះបានបន្តិចទៅ ។ ប៉ុន្តែ ជាមានគំនិតរវែកក្នុងចិត្តលះបង់ការចាស់ចាប់ធ្វើការចុងក្រោយ ។ ដូចណាលោកពោលទុកថា "ចាប់ផ្តើមនោះមិនឆ្ពោះត្រង់ណា" ។ ដែលមិនបានសម្រេចការអ្វីឲ្យបានជាប្រយោជន៍ចំពោះខ្លួន ឬចំពោះលោកឡើយ ។ ជនបែបនេះ ក៏ឃ្លានឈ្មោះថាខ្វះមនសិការៈចំពោះការងារ នឹងសេចក្តីព្យាយាមមិនរួញរាហ្នឹងឯង ។

គំនិតដែលគិតផ្សងតាមជោគជតា ធ្វើឲ្យមនុស្សមានសេចក្តីរួញរា ដោយយល់ថាខ្លួនគ្មានជោគវាសនា ឬជួនកាលវង់ចាំមានជោគល្អសិនសឹមធ្វើការងារ ។ ការពិតនោះ ជោគវាសនាហ្នឹងឯងមិនសូវជាសំខាន់ប៉ុន្មានទេ ។ ប៉ុន្តែអ្នកណាគិតតែវង់ចាំជោគវាសនាមានមក មុខជាអត់ឃ្លាយស្ទាប់មិនខាន់ ។ ដូចមានរឿងនិទានបុរស ៣ នាក់ : ម្នាក់នោះគេបញ្ជាតថា

មានបុណ្យវាសនានឹងបានគ្រងរាជ្យជាក់ស្តែង ក៏គិតតែពីតអង្គុយចាំដេកចាំរាជរថមកទទួលឲ្យទៅគ្រងរាជសម្បត្តិ មិនគិតខ្វល់ខ្វាយធ្វើការងារ ត្រាតែអត់បាយស្លាប់ទៅ ៗ ឯសម្លាញ់ពីរនាក់ទៀត ខំខ្វល់ខ្វាយធ្វើការងារ ព្រោះគ្រូទាយថា ឥតជោគវាសនា គ្រាន់តែមានសម្បត្តិចាយវាយគ្រប់គ្រាន់ មិនរហេមរហាម ៗ អ្នកខ្លះផ្សងជោគវាសនាទិញឆ្នោតដែលមានផលយ៉ាងស្តួចស្តើងណាស់ ត្រឹម ១% ប៉ុណ្ណោះ ៗ រឿងជោគជតារាសីរបស់មនុស្សយើងនេះ ជារបស់មិនគួរជឿទេ អ្នកដែលជឿគ្រូទាយ ក៏គិតតែដេកចាំជោគឥតធ្វើការអ្វី ជាពួកមិនគិតចេញទុនអ្វី គិតតែឲ្យខាងបានចំណេញតែម្យ៉ាង តើគំនិតនេះសមហេតុផលទេ?

មានជនានុជនជាច្រើន មិនសូវនឹកគិតរលឹកដល់ពេលវេលាដ៏មានដំឡៃរបស់ខ្លួន ដែលកន្លងរំលងទៅរាល់ៗ ថ្ងៃ ដោយមិនបានធ្វើប្រយោជន៍អ្វី ៗ ប្រសិនបើនឹកឃើញមុខជានឹកស្តាយក្រោយច្រើន អ្នកខ្លះបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងអបាយមុខ គិតតែខាងស៊ីផឹកដើរលេងសប្បាយទៅតាមរោងមហោស្រពផ្សេង ៗ រាល់ថ្ងៃ ៗ ប្រសិនបើគេគិតថា គេកើតមកគិតតែពីខាងសប្បាយមួយមុខ ឥតគិតដល់កេរ្តិ៍ឈ្មោះកិត្តិយស ឬសេចក្តីចំរើន ឬវិនាស ក៏លើកទុកទៅចុះ ព្រោះមនុស្សបំពួកនេះ បើមានភាគច្រើនក្នុងលោក មុខជាធ្វើលោកទាំងមូលឲ្យទៅជាសត្វលោក មិនមែនជាមនុស្សលោកដូចសព្វថ្ងៃនេះទេ ប៉ុន្តែមនុស្សយើងគ្រប់

រូប រមែងមានខួរក្បាលសម្រាប់ហាត់រៀនប្រើការជាប្រយោជន៍បានគ្រប់ខណៈ ហើយអត្ថប្រយោជន៍នេះ កាលបើកាន់តែលូតលាស់ចំរើនឡើងៗ នឹងជួយបំពេញសេចក្តីខ្វះខាតរបស់ប្រទេសជាតិ បានជាអនេកប្រការ អ្នកដែលបានកសាងសេចក្តីចំរើនដល់ប្រទេសជាតិ បានច្រើនត្រឹមណា ក៏ត្រូវសមនឹងកេរ្តិ៍ឈ្មោះក៏ចារឹកជាប់នៅក្នុងប្រវត្តិសាស្ត្ររបស់ជាតិ អស់កាលជាយូរអង្វែងដរាបនោះ ៗ ហេតុដូច្នេះ ទើបយើងត្រូវតែចេះប្រើពេលទំនេររបស់យើង ឲ្យបានសម្រេចជាអត្ថប្រយោជន៍ដល់ខ្លួនយើង ដរាបដល់វង្សត្រកូលប្រទេសជាតិរបស់យើង សូម្បីក្នុង១ថ្ងៃត្រឹម១ម៉ោង មួយខែ ៣០ ម៉ោង មួយឆ្នាំ ៣៦៥ ម៉ោង ចុះដល់ ១០ ឆ្នាំទៅ តើប៉ុន្មានម៉ោង? — ការសិក្សារបស់គេក្នុងមួយឆ្នាំជាង ១.០០០ ម៉ោងប៉ុណ្ណោះ ក៏អាចញ៉ាំងផលសម្រេចជាអនេកប្រការរាល់ៗ ឆ្នាំ ៗ បើលោកចេះប្រើពេលទំនេររបស់លោក ត្រឹម១ថ្ងៃ ១ ម៉ោង ឬ ២ ម៉ោង សម្រាប់ការសិក្សា លោកក៏នឹងមានចំណេះ កាន់ចំរើនឡើងមិនមែនតិចឡើយ មានឧទាហរណ៍ដូចវិញ្ញូជន ដែលចេះប្រើពេលទំនេរត្រឹម ១ ថ្ងៃ ១-២ ម៉ោងប៉ុណ្ណោះ គេអាចសរសេរវចនានុក្រមបានជាច្រើនភាគ ហើយមានវិញ្ញូជនខ្លះ អាចហាត់និយាយភាសាផ្សេងៗ បានដល់ ១២ ភាសា ព្រោះចេះប្រើពេលទំនេរត្រឹម១ថ្ងៃ ១ ម៉ោង២ ម៉ោងប៉ុណ្ណោះ ៗ

ឥអំពីនេះទៅ ល្មោកនឹងយើញថា ការប្រើពេលទំនេរឲ្យមានប្រយោជន៍នោះ គឺជាការសំខាន់ជូចម្តេចខ្លះ? -

អស់លោកអ្នកដែលធ្លាប់ធ្វើការមកយូរៗ ហើយ ឡានទទួលផលកំរៃនៅដដែល មិនកើនចំរើនឡើងសោះ នោះបើគេចេះប្រើពេលទំនេរស្វែងរកប្រយោជន៍តទៅទៀត នឹងមានកំរៃកើនចំរើនឡើង ឡានធូរចាយសប្បាយចិត្តប្រើនមិនខាន ។

កិលហ្វាវ៉ាដេយ៍ ជាអ្នកឡាជ្ញវិទ្យាសាស្ត្រជាតិអង់គ្លេសយ៉ាងល្បីល្បាញ កាលពីក្នេងទីទាល់ក្រណាស់ ធ្វើការហាត់ដេរក្របសៀវភៅនៅ រោងពុម្ព១ដោយតតឡានទទួលឡាក់រង្វាន់ឈ្នួលទេ តែកុមារនេះឡានចំប្រើពេលទំនេរៗ ដែលនៅសល់ពីការហាត់ដេរក្របសៀវភៅនោះ ចំពិនិត្យមើលសៀវភៅទាំងឡាយ ដែលគេយកមកជួលដេរក្របនោះ ស្ទើរតែគ្រប់ៗ សៀវភៅ ទើបបណ្ណាលឲ្យសេចក្តីចេះដឹងរបស់ហ្វាវ៉ាដេយ៍ កាន់តែរីកចំរើនឡើង ហើយជួបជួនជាមានគេយកសៀវភៅ "តនស៊ីក្លូប៉ីឌ្យ ប្រីតានិ្នក" មកឲ្យដេរក្រប កុមារក៏ប្រើកមើល ឡានប្រទះត្រង់កន្ទែងដែលនិយាយពីវិជ្ជាអគ្ពិសនី ក៏នឹកក្នកចង់ចេះដឹងក៏សាកល្បងលមើល ឃើញផលជាក់ស្តែងហុចជល់គំនិត ។ តាំងពីកាលនោះមក ហ្វាវ៉ាដេយ៍ក៏ចំប្រឹងសិក្សាវិទ្យាសាស្ត្រឡើង តមកឡានអានសៀវភៅវិជ្ជាគីមីដែលមានក្នុងសៀវភៅនោះ ត្រាតែស្ទាត់ជំនាញ ។ ថ្ងៃមួយមានឧកាសឡានចូល

ទៅស្គាប់ចាប់ភកថាខាងវិទ្យាសាស្ត្រ នៅរាជបណ្ឌិត្យស្ថាន មានចិត្តស្ម័គ្រ ចូលទៅធ្វើការក្នុងតំណែងក្នាក់ងារវិទ្យាសាស្ត្រ នៅរាជបណ្ឌិត្យស្ថាននោះ ហ្ការ៉ាដេយ៍ចានសាកល្បងវិជ្ជាអគ្គិសនីនឹងគ្រាប់ គ្រាតែចានជួបប្រទះរឿងផ្សេងៗ យ៉ាងច្រើនបំផុត ។ តមកចានទទួលនាទីជាចាងហ្វាង ហើយចានទទួលកិត្តិយសជានាយកខាងវិជ្ជាហ្ស៊ីស៊ីកនឹងគ្រាប់ ។

គ្មានអ្នកណានឹកនាថា ក្មេងកំសត់ក្ងន់ជាងដំដែក នឹងមានកិត្តិយសកេរ្តិ៍ឈ្មោះល្បី ហើយទៅជាអ្នកប្រាជ្ញវិទ្យាសាស្ត្រយ៉ាងល្បីល្បាញដល់ម្ល៉ោះឡើយ ។

យ៉ាដ្ស៊ីហ្ជូនស៊ីន ជាតួយ៉ាងដ៏គាប់ប្រសើរមួយរបស់មនុស្ស ។ កាលចាប់ផ្តើមធ្វើរបរចិញ្ចឹមជីវិត គេជាអ្នកដីកអណ្ណូងរ៉ែយ៉ាងអ្នកកំសត់ តែមានគំនិតគិតជញ្ជឹងដល់ហានៈរបស់ខ្លួនគួរឲ្យចានគាប់ប្រសើរជាងនេះណាស់ ក៏ស្រាប់តែជុះគំនិតសំខាន់ឡើងក្នុងខួរក្បាលរបស់គេ គឺការគិតសាងតួបក្ររបក្ងើងឡើង ដ្ឋិតនៅក្នុងសម័យនោះ គេនៅនិយមប្រើរនេះសេះនឹងរនេះលា សម្រាប់ដឹកនាំសម្ភារៈនឹងអ្នកជិះដោយសារ ដែលនាំមិនស្រួលដល់ការគមនាគមន៍ណាស់ ។ តែខ្លួនគេជាអ្នកទីតាល់ក្រណាស់ គំនិតនេះនឹងកើតផលឬតតផលនៅជាប្រាកដ គេចំធ្វើការដីកធ្យូងថ្ម ចានកំរៃប្រចាំថ្ងៃបន្តិចបន្តួច ទាំងមិនមានផលកំរៃពីផ្ទះជ្រៃទៀតផង ។ ទើបគេកើតគំនិតគិតស្វែងរកផលកំរៃពីខាងក្រៅ ក្រៅពីមុខរបរសព្ទ

ថ្ងៃ គេគិតធ្វើការស៊ីឈ្នួលដួលដេរប៉ះខោអាវ ដុសដុលស្បែកជើង របស់ពួកកម្មករផងគ្នា បានកំរៃកើនចំរើនឡើងខ្លះ ហើយខំសន្សំប្រាក់ កាសសម្រាប់ជាដំថ្លៃសាលារៀននៅពេលយប់ គេមានសេចក្តីកង្វល់ មួយដែលត្រូវទទួលភារៈ គឺបិតាខ្វាក់ភ្នែក ដែលត្រូវគេចិញ្ចឹមបីបាច់រក្សា បើទុកជាមានឧបសគ្គដូច្នេះក៏ដោយគេក៏ឥតរួញរា គោលបំណងរបស់គេ គឺការសាងរថភ្លើងឲ្យបានសម្រេច ។

កាលគេជំណាលរឿងនេះឲ្យអ្នកដទៃស្តាប់ ពួកអ្នកស្តាប់ត្រឡប់ជា បន្តុះថា មានគំនិតឆ្កួតរវើរវាយ អ្នកខ្លះក៏ថា រថក្រអ្នកឯងនឹងធ្វើឲ្យកើត ភ្លើងនេះមិនបាន អ្នកខ្លះថាធ្វើដូចម្តេចកើត បើប្រើដុតភ្លើងដូច្នោះ មុខជា អ្នកជិះរថក្រឈ្លក់ផ្សែងភ្លើងស្លាប់មិនខាន អ្នកខ្លះបន្តុះថា ប្រហែលជា ដល់គ្រាហិនហោចនៃពួកជាងធ្វើរទេះទូកក្តារហើយ ។ ប៉ុន្តែ ១៥ ឆ្នាំ តមក ពួកអ្នកតិះដៀលដល់គំនិតយ៉ាងចំឡែកនោះ ត្រឡប់ងឿងឆ្ងល់ទឹក ស្ងើចពល់គ្នា កាលដែលរថភ្លើងមួយដំបូងរបស់គេ បានចាប់បើកល្បឿន ទៅបានលើផ្លូវដែកព្រមទាំងអ្នកជិះជាចំនួនច្រើន នេះហើយជាគំនិត យល់សប្តិ ត្រឡប់ជាមានមែនពិតឡើងយ៉ាងអស្ចារ្យ ។

លិនគល្ន៍ ប្រធានាធិបតីនៃទ្វីបអាមេរិកក្នុងសម័យមួយ ដំបូងឡើយ ជាក្មេងកំសត់ អាស្រ័យនៅក្នុងខ្ទមតូចមួយ មិនដែលចូលសាលារៀន គ្មានសៀវភៅរៀន គ្មានគ្រូបង្រៀន តែដែលអាចធ្វើជាមនុស្សមានកេរ្តិ៍

ឈ្មោះល្បីល្បាញក៏ព្រោះការហាត់រៀនខ្លួនឯង និងការអាន់ខ្លួនឯង ។ ដែលគេប្រតិបត្តិ គឺរៀនអក្សរដោយខ្លួនឯង ដោយអាស្រ័យពន្លឺភ្លើងទៀនដែលដុតនៅខាងមុខរូម គេជឿថា គេគោរពរៀនឲ្យបានសម្រេច ។

យើងបានដឹងជាក់ច្បាស់ហើយថា សេចក្តីសម្រេចរបស់មនុស្ស នៅត្រង់ខ្លួនឯងតាំងចិត្តពិតជាប្រធាន សេចក្តីនិយមរាប់អានខ្លួនឯងក៏ជាការសំខាន់ណាស់ដែរ ។ មានចំនួនដែលគួរឲ្យស្តាយពេក ចំពោះយុវជនក្នុងសម័យសព្វថ្ងៃនេះ ច្រើនមានគំនិតមិនរហ័សរួសរាន់ទាន់ការ សម័យរបស់លោក ដែលចំណែនឡើងយ៉ាងនាប់រហ័ស ហើយគេគិតយល់ដល់ហាន: នឹងការរបររបស់ខ្លួន ចាស្ថិតត្រង់ត្រាន់សម្រាប់ខ្លួនហើយ ឬដោយចំនួនខ្ជិលប៉ុណ្ណោះ ទើបគេមិនចំប្រឹងខ្ជាយស្វែងរកអត្ថប្រយោជន៍ផ្លូវតទៅទៀត ។ មានខ្លះយល់ខុសថា ការស្តួល ១ ងាយ ១ ជារបស់គាប់ប្រសើរសម្រាប់ជីវិតរបស់ខ្លួន ទោះបីបានប្រាកដ្ឋានៅរៀវត្សបន្តិចបន្តួចក៏ដោយ ជនពួកនេះមិនបានក្ងកនឹកដល់ធម្មជាតិ ដែលបានប្រគល់សតិបញ្ញានឹងសមត្ថភាពមកដល់ខ្លួនគ្រប់ ១ រូប តាំងពីមកចាប់កំណើតក្នុងនាលោកិយនេះ ហើយត្រូវតែប្រើសមត្ថភាពនោះសោះ ។

តាមដោយពិតនោះ នៅប្រទេសយើងសព្វថ្ងៃនេះ មានជនដែលបានទទួលការសិក្សាមកហ្មត់ចត់ណាស់ ។ អ្នកដែលចង់ចេះចង់ដឹងច្រើនផ្ទះ ត្រូវតែខំសិក្សាដោយខ្លួនឯង គោងយកចិត្តទុកដាក់អានប្រវត្តិ

របស់មនុស្សសំខាន់ៗ ក្នុងលោក ដើម្បីជាផ្លូវគំនិតសម្រាប់ប្រកបកិច្ចការ ផ្ទាល់ខ្លួន នឹងជាប្រយោជន៍ដល់ប្រទេសជាតិតទៅ ។ ប៉ុន្តែគួរឲ្យស្តាយ ពេក ហើយគួរឲ្យអាណាចអាធ័មណាស់ ចំពោះប្រទេសខ្មែរយើង សព្វថ្ងៃនេះ មិនសូវមានសៀវភៅចុះពុម្ពផ្សាយសម្រាប់ប្រជាជនអាន ប៉ុន្មាន មានតែសៀវភៅផមិអាចនឹងចាស់ចាត្ងូបន្ទ្ចបន្ទ្ច សម្រាប់សិក្សា ខាងផ្លូវសាសនា ។ រួមសេចក្ដីខ្ញុំ ទៅស្រុកខ្មែរ ពាក់ងមូលមិនមានមាន ពេងពុម្ពនឹងសៀវភៅចុះពុម្ព ឲ្យសមនឹងឋានៈរបស់ប្រទេសទៅទ្បើយ ទេ ត្រង់ណេះត្រូវបង្ហ្ជនរួមជាតិ ព្ជតដ្ជគ្ជាកសាងឲ្យបានចំរើនទ្ជៅ ទើបប្ជជាជាតិយើង ធ្ជើដំណើរទៅមុខបានរហ័ស បើមិនដូច្នោះទេ មុខ ជារលំរលាយជាតិ ឬជាខ្មែរ ក្ជ ខ្ជ ទ្ជ ក្ជ ាយទៅជាជាតិដទៃមិនមាន ។

ទៅនានាប្រទេស គេនិយមពាប់អានការអានសៀវភៅ សំខាន់ ជាងការមើលកុនមើលល្ងានច្រើនណាស់ ។ ប្ជជាជនរបស់គេ ត្ជ ប់ថ្ងាក់ ច្រើននិយមមើលការសិតកាលថ្ងៃ យ៉ាងហោចណាស់ក្នុងមួយថ្ងៃ ២ ម្ជ ាប់ ត្ជ ៅពីនេះទៅនិយមអានសៀវភៅ របស់អ្នកនិពន្ធដ្ជ ដ្ជ ល មានកេ្ជ ត្ជ ណ្ជ ្ជ ះ ទ្ជ ៀតកាលថ្ងៃ ដើម្ជ ីជាបច្ជ ័យជ ុ ំ ជ ួ ជ ជ ាត ់ ខ ្ ជ ួ ក ្ ជ ា ល ជ ប ់ ស ់ គ ជ ៀ ្ ក ្ ជ ី ជ ា ។ ហ ជ ត ុ ដ ្ ជ ូ ច ្ ជ ះ ទ ្ ជ ើ ប ជ ជ ាច ជ ុ ះ ព ុ ម ្ ជ ស ្ ជ ៀ ្ ភ ្ ជ ៅ ច ំ ណ ្ ជ យ ជ ជ ញ ្ ជ ៅ ព ាប ់ ហ ្ ជ ឿ ន ព ាប ់ ស ្ ជ ន ក ្ ជ ា ល ជ ួ ន ្ ជ ា ល ព ាប ់ ្ ជ ា ន ក ៏ ្ ជ ា ន ។

មានតែការអានសៀវភៅប៉ុណ្ណោះទេ ដែលធ្វើឲ្យអ្នកមានខ្ជះខ្ជាយ ឈ្មោះសរសៃពាន់សម័យនិយម ។ សៀវភៅល្អ ១ ដែលមានសារប្រយោជន៍ អាចនឹងធ្វើជីវិតនឹងហានៈរបស់អ្នកឲ្យបានថ្លៃនុងរឿងជាអនេកប្រការ ដូចពួកមហាបុរសក្នុងលោកធ្លាប់ធ្លាប់ប្រព្រឹត្តមកហើយ មានអាទិដូចជា ហ្ការ៉ាដេយ៍ពិត្តនាយករដ្ឋមន្ត្រីអង់គ្លេសក្នុងសម័យមួយ នឹង លិនគ្ល ប្រធានាធិបតីអាមេរិក ដែលមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់ ព្រោះការអានសៀវភៅនេះឯង ។ ណាប៉ូលេអុង ចក្រពត្តិចាវ៉ាន់សែស ក៏ទ្រង់យកព្រះរាជហឫទ័យទុកដាក់នឹងការអានសៀវភៅយ៉ាងវៃក្លែង ។ ហ្ជានស៊ីសបេទនពោលថា "ការអានសៀវភៅ ធ្វើមនុស្សឲ្យជាមនុស្សបរិបូណ្ណ:" ។ តែការអានសៀវភៅនេះ ក៏មិនមែនជាការងាយស្រួលដែរ ព្រោះសៀវភៅនិមួយ១ រមែងមានពាក្យរឿងល្អ - អាក្រក់ច្រឡំគ្នា ទើបមុននឹងអានសៀវភៅអ្វីនោះ គួរតែសរសេមើលសៀវភៅណាដែលល្អ១សិមអាន ព្រោះសៀវភៅល្អ១ ជាតួបាយជាស់ភ្ជាន់ត្រឹនរំលឹកចិត្តគំនិតឲ្យទៅជាអ្នកនិពន្ធមានកេរ្តិ៍ឈ្មោះល្បី ឲ្យកើតមនុស្សធម៌ ឲ្យកើតវិទ្យាសាស្ត្រ ឲ្យកើតមនុស្សសំខាន់១ ក្នុងលោក ។ ហេតុដូច្នេះកើតចោរចិត្តយ៉ារយ៉ាងសម្រាប់ត្រៀមតាញ ញើតដៃ ដូច្នេះការជ្រើសរើសមើលសៀវភៅសិនសិមអាន ទើបមានប្រយោជន៍យ៉ាងសំខាន់សម្រាប់ជីវិត ។

សៀវភៅជាមិត្តល្អរបស់មនុស្ស យើងបានសប្បាយរីករាយចិត្តនឹងសារប្រយោជ៍នអំពីសៀវភៅ សៀវភៅឥតមានពេលប្រែប្រួលទេ បើទុកជាបានទុក្ខសោកយ៉ាងណាក៏ដោយ សៀវភៅល្ងងលោមចិត្តក្នុងត្រាមានទុក្ខ នាំឲ្យសប្បាយរីករាយនៅពេលទំនេរ សៀវភៅមិនបោះបង់ឲ្យយើងនៅតែម្នាក់ឯង យ៉ាងកណ្តៀងកណ្តោច ក្រៅពីនេះ សៀវភៅជាត្រឿងជាស់ត្រឿនចិត្តឲ្យយើងទំទ្វីឃ្មាត ហើយនៅជាយុវជនទាន់សម័យជានិច្ច ។

ចប់

រឿងក្មេងតាំង្រា (រឿងត្រែង)

ឃុន ឫទ្ធីវ៉ាកភ័ណ្ឌ ឈ្ម - ណាត ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ជនប្រុសស្រីដែលមានចិត្តជ្ញាញ់ជ្ងាវ ធ្លៀងធ្លាសធ្លាប់ប្រើគំនិតក្នុងការគិតរកប្រយោជន៍, ត្រូវប្រកបដោយសេចក្តីព្យាយាម ដែលទាក់ទងដោយ១ចុងនៃចិត្តជ្ញាជាគ្រឿងត្រិះរិះសព្វ១ការ; បើមានតែព្យាយាមមិនមានចិត្តជ្ញាជាគ្រឿងត្រិះរិះទេ ក៏មិនបានសេចក្តីចំរើន, លុះតែព្យាយាមប្រកបដោយបញ្ញា ទើបបានសេចក្តីចំរើនគ្រប់យ៉ាង ដូចមាននិទានរឿងត្រែងជា១ទាហរណ៍តទៅនេះ:

មានបុរសអ្នកស្រែមួយនាក់ ប្រកបការរបរចិញ្ចឹមជីវិតតែនឹងដាក់ដុចយកត្រីមកលក់ជូរប៉ុណ្ណោះ ។ បុរសនោះមានកូនប្រុសពីរនាក់, កូនបងអាយុ ១៣ ឆ្នាំ, កូនប្អូនអាយុ ១១ ឆ្នាំ ។ ប្រពន្ធស្លាប់ទៅគាត់ទៅពោះម៉ាយជាមួយនឹងកូនពាំងពីរ ហើយរកស៊ីចិញ្ចឹមកូនតែនឹងដាក់ដុចជាដែល ។ រៀងរាល់ដែលបុរសនោះទៅត្រែកចុះចល្ងាច-ផ្ដៅធ្វើដុច តែងយកកូនបងទៅជាមួយ, ឯកូនប្អូនទុកឲ្យនៅចាំផ្ទះ ។

ថ្ងៃមួយ កូនប្អូនមានសេចក្តីសង្ស័យពេកណាស់នឹងឪពុកទៅត្រែចុះចល្ងាច-ផ្ដៅធ្វើដុច ព្រោះចង់ដឹងឪពុកធ្វើដុចយ៉ាងណា ១ទ្ធមិនដែល

ឃើញសោះ ក៏និយាយប្រាប់ឪពុកថា ឪ! ខ្ញុំមិនហ៊ានទៅផ្ទះតែម្នាក់ឯងទេ, ខ្ញុំខ្លាចណាស់, សូមយកខ្ញុំទៅដែរជាមួយផង ។ ឪពុកក៏ព្រមយកកូនប្អូនទៅជាមួយ, លុះទៅដល់ដែរ ឪពុកក៏ចុះប្រជ្រៅរកបោចវល្លិ-ផ្ការ ចាន ហើយយកមកពុះច្រៀកជាចម្រៀកតូចៗ ល្មមនឹងធ្វើជាសរសៃដុត, គាត់ក៏រៃធ្វើជាដុតទៅ ។ កូនបងដែលធ្លាប់តែតាមឪពុកទៅដែរធ្វើដុតសព្វៗថ្ងៃ មិនដឹងជាឪពុកធ្វើដុតយ៉ាងណាទេ ព្រោះមិនយកចិត្តទុកដាក់នឹងការងារនោះ គ្រាន់តែចាន់ឃើញជាដុតជាប់ត្រីប៉ុណ្ណោះ ។ ឯ-កូនប្អូនដែលទើបតែនឹងចាន់តាមទៅក្នុងថ្ងៃនោះ ក៏ចាប់ពិនិត្យមើលឪពុកធ្វើដុត ចាប់តាំងពីការកាំបិតយកទៅកាប់វល្លិ-ផ្ការ រហូតដល់កើតជារាងដុតយកទៅដាក់ត្រី ជាប់ចាន ត្រីហើយ យកត្រីមកដុតអាំងចំអិនជាចំណីអាហារ ។

ជួនណាថ្ងៃនោះ ឪពុកភ្លេចមិនចាន់យកឈ្នាន់ទូសទៅ, គ្មានអ្វីនឹងបង្ហាត់ភ្លើងអាំងត្រីឲ្យកូនប្រុសកាត, ក៏ទៅកាប់ឫស្សីស្ងួតហែងមួយកំណាត់ យកមកកូតនឹងគ្នាឲ្យតាលតែភ្លេវកើតជាភ្លើងនេះចាន ហើយគាត់បង្ហាត់អាំងត្រីឲ្យកូនតាំងពីរនាក់ប្រុសកាតចំអែតថ្ងៃមួយពេល ។

ចំណែកចិត្តកាលមកវាងក្រោយ ឪពុកមានជម្ងឺជាទម្ងន់ដល់ទ្រមរ-ណាភាព ។ កូនតាំងពីរនៅកំព្រាតែងតែ ឥតមេ - ឪពុកនឹងចិញ្ចឹមជីវិតប្រាប់ថ្ងៃ ក្យា ទៅអាស្រ័យចិញ្ចឹមជីវិតដោយទ្រព្យបន្ទិចបន្ទួចដែលសល់ពីឪពុក ។

មិនយូរថ្ងៃ-ខែប៉ុន្មាន ក៏អស់ទ្រព្យនោះទៅ ។ ទើបប្អូននិយាយនឹងបងថា ឱបងអើយ ! យើងកាលពីដើមបានឪពុកទំនុកបំរុងរកស៊ីចិញ្ចឹមយើងទាំងពីរនាក់, យើងឥតមានសេចក្ដីព្រួយលំបាកអ្វីឡើយ ចាំតែទទួលទានស្រាប់ៗ; ឥឡូវនេះឪពុកយើងស្លាប់ចោលទៅហើយ, ឯយើងទាំងពីរនាក់សោតទៀតក៏មិនទាន់ពេញកំឡាំងល្មមនឹងរកស៊ីចិញ្ចឹមជីវិតបានដោយខ្លួនឯង, ទាំងបងក៏នៅតូច ទាំងខ្ញុំក៏នៅតូច នឹងទៅរកស៊ីឈ្នួលឈ្នួលពីអ្នកជិតខាងក្រែងគេមិនព្រមទទួល ពីព្រោះយើងជាមនុស្សកំព្រាអនាថារកទីពឹងគ្មាន គេមិនហ៊ានឲ្យនៅជាមួយ គេមិនទុកចិត្តយើង ហេតុតែយើងគ្មានមេបាថែរក្សា; បើដូច្នេះ តើបងគិតយ៉ាងណាទើបនឹងបានរស់នៅជាមួយនឹងគេឯង, បង! អង្ករថ្ងៃនេះនៅតែ ១ ទូកដៃល្មមតែល្ងាចនេះ ថ្ងៃស្អែកគ្មានអង្ករដាំបាយបរិភោគទេ, បង! ដើរសូមទានគេឬដូចម្ដេចហ្នះ! ខ្ញុំមិនទៅសូមទេ ខ្មាសគេណាស់ ស៊ូតែពីស្លាប់ ។ ម្ដេចក៏ប្អូនថាយ៉ាងនេះ? បងសួរប្អូន ។ ប្អូនឆ្លើយតបទៅនឹងបងថា ខ្ញុំមានដៃពីរជើងពីរ គំនិតមារយាទដូចអ្នកទាំងពួងដែរ ។ ឱ! ប្អូនឯងគិតយ៉ាងហ្នឹង! ពិតមែនតែមានដៃពីរ ជើងពីរ គំនិតមារយាទដូចអ្នកទាំងពួងមែនហើយ តែខ្លួនយើងនៅតូចណាស់ មិនអាចនឹងទៅពុនរែក កាប់គ្រាស់ លី-សែងអ្វីបានឡើយ ។ ឱ! បងអើយ! សត្វចាបក៏ដែលទៅពុនរែក លី-សែងឯណាដែរឬ? ម្ដេចក៏វាចិញ្ចឹមកូនវារស់

ហើយកូនក់ទៀតធ្លើងកស៊ីដូចមេក់ទៀតបាន ចុះបងម្តេចក៏មិនគិតដល់ការងាររបស់ឥតុកយើងផង? ។ ប្អូន! លាក់ចុងអ្វី កាលពីភ្នែចនៅរស់ឡើយ គាត់រកស៊ីចិញ្ចឹមយើងតែនឹងដាក់ដុច, ប៉ុន្តែបងមិនដឹងជាគាត់ធ្លើដុចយកទៅដាក់ត្រីយ៉ាងណាទេ បងចាំតែឆ្ងិនតែម្តង ។ ម្យ៉ាងទៀត កាលគាត់យករបស់អ្វីមកធ្លើដុចក៏បងមិនចាំ ហើយគាត់ធ្លើដុចនោះមានសណ្ឋានបែបណាក៏បងមិនដឹងច្បាស់អស់,បើដូច្នេះ ឲ្យបងធ្លើដូចម្តេចកើត! យើញតែការសូមទាន ឬស៊ីឈ្នួលគេហ្នឹងហើយដូចជាស្រួលគ្រាន់បើ; ប្អូនណ្ហើយចុះគាត់ក្តេ្ចវ្ចាសសិនទៅចុះ ទម្រាំយើងធំលូមរកស៊ីខ្លួនឯងបាន ។ ទេ! បង, ខ្ញុំមិនទៅសូមទានឬស៊ីឈ្នួលគេទេ ភ្ជាសគ្រាន់ ពីព្រោះពួជយើងមិនដែលសូមទានឬស៊ីឈ្នួលគេ, បើទុកជាតាមតាតួត - លួតលាមក ធ្លាប់សូមទានឬស៊ីឈ្នួលឲ្យកំឡាងគេប្រើដូចជាសត្តិរច្ឆានក៏ដោយ ក៏ខ្ញុំមិនព្រមប្រតិត្តតាមបវេណីវង្ស្ត្រកូលនោះដែរ នៃបង, ប្អូនគិតយើញថា: កាលបើមានអ្នកសប្ប្ស្ដសចិត្តល្អដាក់ទានឲ្យយើងឬក៏ចាងទៅជ្ជកកោនឧ្ចាជាទៅហ្ការ យើងក៏ចាងស្រួលបន្ត្ចិចទៅ; តែបើប្ចទ:ពារទៅលើអ្នកចិត្តតក់ម៉ាក់ អ្ចាក្ត ពេកកូវសំឡ្ចាក្ដែកស្ដ ដូចក្ដែកមៀម គ:ហកគ្រាមយើងដូចសត្តិរច្ឆាន តើយើងយកមុ:ទៅទុកឯណា? ម្យ៉ាងទៀត អ្នកចិត្តល្អ ក្ដី អ្នកចិត្តអ្ចាក្ត ក្ដី កាលគេហ្ចុ:ចរបស់ឲ្យមកយើងដោយដៃគេ យើង

យកដៃទៅទទួលទានគេ ចុះដៃជាដៃ ដើងជាដើង មាត់ជាមាត់ ដូចគ្នាទាំងអស់ ម្តេចក៏ដៃគេគ្មានសំពះសុំអ្នកណា មាត់គេមិនហានិយាយសូមអ្នកណា អន់អ្វីតែដៃដើងមាត់យើងជាងគេម្ល៉ះ, បងគិតមើលចុះ ប្អូនចាប់ណ្ណែនខ្ញុំសម្ត្រៃ? ។ បើដូច្នោះ ប្អូនចេះចាំការងារបស់ឧត្តុកយើងដែរឬ? បងសួរគេបទៅប្អូនវិញ ។ អើ មិនអីទេបង! ប្អូនចាំទាំងអស់ បងកុំព្រួយ កុំគិតទៅសូមទានឬស្តីឈ្លួលឲ្យកំឡាំងគេប្រើ ក៏ថាកខ្ជិនណាស់ យើងនេះមិនមែនជាសត្តិតិរច្ឆាន គេក៏យកឯកើតទៅឯលិចដូចសុនខពេកទេ ឧត្តុកគាត់ទុកកាំបិតព្រាឲ្យមួយដែរតើ! យើងទៅព្រួយអីសព្វបើគ្រាន់តែចិញ្ចឹមជីវិតមួយប៉ុណ្ណឹង ។ អើ! ប៉ុន្តែ យ៉ាងហ្នឹងប្អូនគិតធ្វើការងារឧត្តុកទៅចុះ ។

ឯប្អូនជាកូនមានប្រាជ្ញា ក៏ប្រាកដធ្វើដុចកើតយកទៅជាក់ត្រីបានដូចបំណង ។ លុះកន្ទ្ងមកថ្ងៃក្រោយទៀត ប្អូនអង្គុយគិតតែម្នាក់ឯង មិនចេញវាចាប្រាប់បងសោះថា: ឧត្តុកអញគាត់ចេះតែធ្វើដុចជាក់ត្រីប៉ុណ្ណោះ ត្រង់សត្វឯទៀតៗ គាត់ជាក់ដុចមិនបាន ឃើញថាប្រាជ្ញាគាត់ទៅខ្សោយណាស់ បើដូច្នេះអញរកឧបាយនឹងធ្វើដុចជាក់សត្វម្ចឹត មានសត្វដូកត្រៃ ឈ្លូស រមាំងជាដើម លុះគិតដូច្នោះហើយ ក៏និយាយប្រាប់បងថា បង! យើងគិតទៅរកជាក់ដុចឯត្រៃវិញ ត្រែងបានជាប់ដូកត្រៃឈ្លូស រមាំង ជាសត្វធំៗ បានសាច់ច្រើន ។ បងក៏សុខចិត្តតាមប្អូនទាំងអស់

ព្រៃ១យល់ឃើញថា ប្អូន១នេះចាកចូ្ចការរបស់ឪពុកពិតប្រាកដមែន, ហើយក៏បណ្តើរគ្នាពីនាក់បងប្អូន ចូលទៅក្នុងព្រៃស្រោងដាទីរហោស្ថានទៅដល់ពាក់កណ្តាលព្រៃ បងស្រែកទឹកយ"ងខ្លាំងនិយាយប្រាប់ប្អូនថា ប្អូន ! បងស្រែកទឹកណាស់ រកទឹកឯណាផឹកបាន ។ ប្អូនធ្វើយថា ការពិឪពុករស់នៅ បើដើរទៅទីណាដែលគ្មានទឹកគាត់ដឹកដ៏ត្រង់ក្នែងណាសើមៗយូរៗ ទៅចេញទឹកបាន បើដូច្នេះបងដឹកលមើល ? ដឹកឯណាកើត បើអស់កំឡាំងយ"ងនេះ ។ អើបើដូច្នោះចាំដើរទៅខាងមុខបន្តិចសិនត្រែងដួនប្រភេទទឹក, ដើរបានបន្តិចទៅក៏ជួបប្រភេទនឹងត្រពាំងមួយមានទឹកថ្លាពាសពេញដោយផ្កាឈូកផ្ទៃឈូក ; បងប្អូនទាំងពីរនាក់ក៏នាំគ្នាផ្ទួតទឹក-ផឹកទឹកបេះផ្ទៃឈូកស៊ីតាមសប្បាយ ហើយក៏សម្រាកនៅកន្ទ្រមាត់ត្រពាំងនោះមួយស្រមុក ។ លុះមានកំឡាំងល្មមនឹងដើរទៅទៀតបានក៏នាំបងប្អូនដើរទៅ ; លុះបានទៅដល់ព្រៃធំមួយឈ្មោះព្រៃហ៊ីមពាន្ត មិនដែលមានមនុស្សណាទៅដល់សោះ, បានឃើញពួកសត្វម្រឹគជាច្រើនទៅអាស្រ័យក្នុងព្រៃនោះ ប្អូននិយាយនឹងបងថា បង ! យើងឈប់ទៅក្នុងព្រៃនេះហើយ មើលទៅព្រៃនេះសម្បូណ៌សត្វម្រឹគ៍ម្រឹគាណាស់; យើងគិតធ្វើផ្ទះមួយនៅលើចុងឈើ ហើយខ្ញុំរកចុចផ្តៀមកធ្វើផ្ទុចដាក់សត្វទាំងនោះយកមកធ្វើជាចំណីអាហារ ។ ប្អូនធ្វើផ្ទះលើចុងឈើរួចហើយ ឲ្យបងនៅអាស្រ័យលើផ្ទះនោះទៅ ខ្ញុំនៅរក

ប្រាប់ផ្តៅយកមកធ្វើដុបដាក់សត្វព្រៃ រៀបធ្វើជាបំណាវបារជុំវិញព្រៃ ហើយទុកតែផ្លូវ ១ ល្មមសត្វនោះដើរចូលបាន ដូចជាធ្វើកន្ទ្រងដាក់ត្រី ដែរ ។ ពេលនោះមានសត្វជ្រូកព្រៃមួយដើរសំដៅពីនាយ ហាក់ដូចជាគ្មានកោតក្រែងដល់អ្វីសោះ ដើរមកតាមចន្លោះផ្លូវដែលកុមារនោះចារ ទៅដល់ត្រង់កន្ទ្រងដាក់ដុប ក៏ស្រាប់តែជាប់ក្នុងដុបកុមារ ជ្រូកនោះទំបំរះទទៀលរើយ៉ាងណាក៏មិនរួច ដុបរឹតរួតជ្រូកព្រៃនោះយ៉ាងតឹងស្វិតតែជកដង្ហើមមិនរួច, មិនយូរប៉ុន្មានជ្រូកនោះក៏ដាច់ខ្យល់ស្លាប់ទៅ ។ កុមារទាំងពីរឃើញជ្រូកព្រៃជាប់ដុបស្លាប់ដូច្នោះហើយ ក៏ត្រេកអរពេកណាស់ នាំគ្នាដោះអូសចេញពីដុប យកមកអាំងធ្វើជាអាហារបរិភោគ ។ ដូនជាវេលានោះ, ឈើគូសដែលដាក់ក្នុងហោប៉ៅអាវបងក៏អស់គ្រាប់ គ្មានអ្វីជាភ្លើងនឹងបង្កាត់អាំងជ្រូក; បងភាល់គំនិតស្ញេញ មិនដឹងគិតធ្វើយ៉ាងណា; ឯប្អូនជាក្មេងមានគំនិត បានដឹងជាក់ប្រាកដពីកាលឪពុកនៅនាំទៅព្រៃ បើគ្មានភ្លើងបង្កាត់បំអិនអ្វីៗ គាត់តែងទៅកាប់ឫស្សីស្ងួតមកកួតកើតជាភ្លើងដុតអាំងបានតាមប្រាថ្នា ហើយបានកំណត់ទុកក្នុងចិត្តរួចស្រេច ។ វេលានោះប្អូននិយាយប្រាប់បងថាកាលពីឪពុកយើងគាត់នៅ បើគាត់ទៅព្រៃគ្មានភ្លើងដុតអាំងអ្វី ៗ គាត់កាប់ឫស្សីយកមកកួតគ្នាកើតជាភ្លើងបាន, បើដូច្នោះ បងនៅចាំសត្វក្នុងទីនេះចុះ ខ្ញុំទៅរកកាប់ឫស្សីស្ងួតយកមកកួតធ្វើភ្លើងអាំង ចាំតែប៉ុណ្ណោះ

ហើយ ក៏ទៅរកកាប់ឫស្សីបានយកមកធ្វើតាមតម្រាប់ឪពុកកើតមែន ទាំងផ្អើរដែកនោះទៅតាមបំណង ផ្អិនបានបរិភោគក្នុងវេលានោះទៅ ៗ កុមារទាំងពីរ នៅអាស្រ័យក្នុងព្រៃនោះអស់កាលជាយូរបានសេចក្ដីសុខសប្បាយ រកស៊ីតែទីងដាក់ផុបសត្វព្រៃប៉ុណ្ណោះ ៗ ពួកសត្វដែលដើរមកជាប់ផុបកុមារទាំងពីរនោះ តាំងតែពីសត្វជ្រូកព្រៃ - រមាំង - ឈ្លូស រហូតដល់ជាប់ដំរី ៗ រាត្រីមួយ កុមារប្អូនបានឃើញដំរីស្ដួមួយយ៉ាងធំដើរក្បែរផ្ទះនោះ ក៏មានបំណងចង់ស៊ីសាច់ដំរី, និយាយប្រាប់បងថា: ខ្ញុំចង់ស៊ីសាច់ដំរីណាស់, ដ្បិតមានដំរីស្ដួមួយយ៉ាងធំណាស់ដើរមកក្បែរផ្ទះយើងរាល់រាត្រី, ខ្ញុំគិតដាក់ផុបយកដំរីនេះឲ្យបាន ៗ បងនិយាយឃាត់ថា: ណ្ហើយប្អូនកុំ. ដំរីនេះធំណាស់ ប្អូនដាក់វាមិនជាប់ទេ ឬថាប្រសិនជាវាដើរមកជាប់ផុបប្អូនហើយវាបំរះត្រដរួចទៅនោះវាខឹង, កាលបើវាខឹងហើយ ថ្ងៃក្រោយវាមកព្រេចផ្ទះយើងល្អិតល្អោចខ្ទេចខ្ទី ហើយវាជាន់សម្លាប់យើងស៊ីជាចំណីអាហារពុំលែងឡើយ ៗ ទេ! មិនអីទេ; បងកុំព្រួយនៅតែឲ្យស្ងៀមទៅចុះ ចាំមើលខ្ញុំធ្វើផុបដាក់ដំរីនេះឲ្យទាល់តែបាន; ប្អូនថាដូច្នោះហើយ ក៏រកកាប់ផ្ដៅក្រកយ៉ាងធំៗ យកមកវេញធ្វើជាផុប ដាក់ត្រង់កន្លែងដែលដំរីគោចរ ៗ

ឯដំរីដែលដើរទៅមកសព្វរាត្រី ឥតមានគិតក្រែងអ្វីសោះឡើយ ដោយគិតថា: ព្រៃនេះស្រេចលើអញហើយ គ្មានអ្នកណាជាចំបងលើ

អញ្ចេតទេ, ក៏ដើរតម្រង់ត្រង់មកកន្លែងដែលកុមារផ្ទាក់ផុច ស្រាប់តែ
ចូលទៅក្នុងផុចជាប់ទ្រនាប់ផ្ទៀតណែនក្តួន, ទ្រាប់ម្រះនេះលាតស្រែកពេញកំពង
ត្រៃធំយ៉ាងណាក៏មិនរួច មិនយូរប៉ុន្មានផ្ទាប់ខ្សាស់ស្ងាប់ទៅ ។

កុមារទាំងពីរនាក់ឃ្លានឃើញដំរីផ្ទាប់ផុចស្ងាប់ហើយ បក្ខាលបង្ហួន
ចំពក់ក្ងៀងក្ងក់យ៉ាងធំ ជុតផ្ទ្រើដំរី ។ លោនោះ ក្ងិនឈ្ងុយសាច់ដំរីកន្ធ្យាយ
ហួតដល់ពពកជាទីនៅអាស្រ័យនៃយក្ស ដែលមានអំណាចគាចគ្រប
សង្កត់ពួកយក្សឯទៀតៗ ។ យក្សនោះលាន់មាត់ថា: ថ្ងៃនេះធ្លុកក្ងិនសាច់អ្វី
ក៏ឈ្ងុយឈ្ងប់ម្ល៉ះ, មានអ្នកណាផ្ទ្រើសាច់ឯណាអេះ? បើដូច្នេះអញនឹងទៅ
រកមើលត្រែងឃ្លានមួយចំអែត ព្រោះសាច់នេះក្ងិនធ្ងាញ់ណាស, ហើយ
ដោយស្មានទៅប្រហែលជាត្រៃនធ្ងន ឃ្លានជាធ្លុកក្ងិនធ្ងាយមកដល់ទីអញ
យ៉ាងនេះ, អញទៅគ្រាមយកស៊ីទាំងអស់ កុំឲ្យអ្នកផ្ទ្រើនោះវាឃ្លានស៊ី" ។
គិតដូច្នោះហើយក៏ចាប់យកដំបងពេជ្ជគ្រីហោះឡើងលើអាកាសវេហាស
ងាកមើលចុះឡើងឃើញផ្សែងហុយ ។ ត្រង់ត្រៃធំ ក៏ហោះចុះសំដៅទៅ
ត្រង់កន្លែងផ្សែងនោះ, ក្រឡេកមើលទៅឃើញក្មេងតូចពីរនាក់កំពុងតែ
ផ្ទ្រើដំរី គិតថា: ថ្ងៃនេះពេញជាមហាលាភហើយ ឃ្លានទាំងចំណីទាំង
ម្ហូបស់ បើដូច្នេះ តើអញនឹងស៊ីដំរីមុនឬ ស៊ីក្មេងមុនអេះ? បើស៊ីដំរីមុន
ត្រែងក្មេងនេះវាក៏ឃ្លានឃ្ងាតនឹងអញរត់ពួនឃ្លាតទៅ, ត្រូវតែនឹងស៊ីក្មេងមុន ។ ឥឡូវ
អ្វីគ្រាន់ផ្ទ្ងាប់ផ្ទ្ងែម ស ម្រាប់ឈ្ងាងមាត់ទាងត្រៃយ៉ាងនឹងស៊ីដំរីរួច ។

នៅទីបំផុតនោះ យក្សសម្រេចសេចក្ដីថា : ណ្ហើយ អញស៊ីដំរីមុនចុះ ទុកក្មេងស៊ីក្រោយជាបង្អែមវិញ ទើបជ្រះមាត់ស្រួល ក្មេងនេះវាមិនមែនរត់រួចទៅឯណាឡើយ, ទុកជាវារួចកន្លែងណា ក៏មិនកំបាំងនឹងក្លិនអញដែរ វាមកពីស្រុកភូមិរបស់មនុស្សលោកចូលដល់ព្រៃនេះម្ល៉េះហើយ វារត់ទៅណារួច: ទើបយក្សប្រួលគម្រាមកុមារដែលកំពុងផ្អើរដើរនោះថា វ៉ើយអាក្មេងប្រមាក់ អាឯងមកពីណា ? ដើរចេញឲ្យឆាប់ៗ ៗ កុមារទាំងពីរដើរចេញពីទីនោះទៅ: ប៉ុន្តែកុមារទាំងពីរនាក់នោះ កុមារបងមានសេចក្ដីភិតភ័យតក្កមា ព្រោះខ្លួនស្គាល់ច្បាស់ជាយក្ស ហើយបានដឹងប្រាកដអំពីសំណាក់ចាស់ៗ គេនិយាយប្រាប់ថា យក្សខ្លួនធំមានចង្កូមពីរសម្រាប់ស៊ីមនុស្សលោក, តែមិនចេញវាចាប្រាប់ប្អូនឡើយ ៗ ចំណែកខាងកុមារប្អូនគិតថា មនុស្សនេះមកពីណា រូបរាងធំគម្រាំង ធ្មេញធំៗសសាចបុនៗ ចបកាប់, ភ្នែកឡើងក្រឡោតៗក្រហមក្រលែត ដូចភ្នែកអូគ, ស្បែកមុខឡើងងគ្រើតគ្រាត ដូចស្បែកគីង្គក់, ដងខ្លួនដូចក្របីដេកកក់, សំឡេងព្រួតគ្រក់ៗ ដូចជាទឹកដក់ក្នុងរន្ធឈើ, ធុះពុកមាត់ពុកចង្កាស្រមេមស្រមាមដូចបិសាចពជក្កូត អានេះប្រហែលជាមិនខ្លាចកោតញញើតចិត្តអញទេ, បានជាហ៊ានមកនិយាយកំហែងអញដូច្នេះ, មិនអីទេអាឯង ព្រះហើនហ៊ានស៊ីដំរីអញ ៗ កុមារប្អូនថយចេញពីកន្លែងនោះមិនឆ្ងាយប៉ុន្មាននៅឈរមើលយក្សស៊ីដំរី តែក្នុងចិត្តនឹកខ្ញាញ់ពេកណាស់មិនទាន់ចេញស្ដីថាដូចម្ដេចៗ ឡើយ គ្រាន់តែនឹកក្នុងពោះប៉ុណ្ណោះ ៗ

ពេលនោះយក្សសួរថា នែអាក្មេង អាឯងធ្វើដូចម្ដេច បានជាបានដំរីនេះយកមកឆ្អើរ? កុមារតូចបានឱកាសពេលនោះ ឆ្លើយតបទៅយក្សវិញថា ពូឯងសួរចង់ដឹងអ្វី គិតតែពីបរិភោគទៅចុះ កុំចាំបាច់ដឹងហេតុការណ៍អ្វីឡើយ ។ យើ! អាប្រមក់ប្រាប់ឲ្យឆាប់ៗ អញសុំអាឯងទៀតឥឡូវនេះហើយ, យក្សសួរគំរាមកុមារតូច ។ អើ! ដំរីនេះវាដើរមកជាប់ផុចខ្ញុំ កុមារឆ្លើយតបទៅនឹងយក្ស ។ យីអើ! អាឯងធ្វើផុចដូចម្ដេចក៏ដាក់ដំរីបាន អាឯងនិយាយកុហកទេឬ ក្រែងដំរីវាស្លាប់ខ្លួនវាទេដឹង ហើយអាឯងនិយាយបញ្ឆោតអញយ៉ាងនេះទៅ មើលអាឯងនិយាយឲ្យត្រង់កុំកុហក, តែកុហកអញសុំអាឯងទៀតឥឡូវនេះមិនខាន ។ ខ្ញុំមិនចេះនិយាយកុហកទេ ពូឯងមើលចុះផុចខ្ញុំនៅឯណោះហ្ន៎ ។ ប្រាកដជាអាឯងដាក់ផុចដំរីនេះបានមែន យក្សសួរសង្កត់សង្កិនកុមារ ។ មែន, កុមារឆ្លើយតបយ៉ាងស្រពន់ ។ អើ! បើផុចអាឯងពូកែមែន ដាក់អញលងមើល ។ កុមារក៏រត់ទៅយកផុចមក ហើយប្រាប់យក្សថា ពូឯងចង់ដឹងចូលទៅក្នុងផុចខ្ញុំលងមើល ។ ដោយហេតុតែការមើលងាយថា សត្វបើផុចសរសៃរុំៗប៉ុណ្ណោះ អញគ្រាន់តែកម្រើកក៏ដាច់ខ្ទេចខ្ទីដែរ ថាហើយក៏ឥឡូលក្បាលចូលទៅក្នុងផុច ផុតដៃផុតជើងទាំងអស់, ស្រាប់តែផុចរឹតរួតតឹងខ្លួនមើលតែគេចាក់ស្រែះ បម្រះនទៀលបាក់ឈើព្រៃល្អិតល្អោច ស្រែកទ្រហោរំពងព្រៃ បុន្តែយក្សដែលធ្លាប់ពូកែយ៉ាងណា ក៏ប្រមូលយកមកអស់,

រឿងព្រៃងកូមា

លោក សាង - សាវ៉ាត លេខានុការក្រសួងហ៊ិរញ្ញវត្ថុ

ប្រែបេញពី សៀវភៅកុងប៉ីវ៉ង (Contes birmans) រចស់លោកល្វីវុស្សុង (Louis Vossion)

ជាភាសាបារាំងមកជាខ្មែរ

ព្រាហ្មណ៍ ងឹងផ្លែ

ជនណាទុកចិត្តមនុស្សទើបស្តាល់

ចាស់លោកហ៊ានគ្នាល់គង់ត្រូវចុាក

រឿងនេះ មានយូរអង្វែងណាស់មកហើយ ។ គឺកុងសករាជព្រះ ពុទ្ធផូម៉ាណា (Thoumana) ទី ១៣ ។ មានព្រាហ្មណ៍ម្នាក់ ឈ្មោះ អាហ៍ មន់ដា (Ahmanda) ដែលរស់នៅកុងស្រុក ស៊ីកាមា (Jikama) ។ ថ្ងៃមួយ នៅពេលដែលព្រះសុរិយាហៀបអស្តង្គត់រលត់ទៅ ព្រាហ្មណ៍នោះ ចុានចូលទៅកុងព្រៃដើម្បីលុបលាងខ្ជូនកុងទឹកជ្រោះជិតខាង ហើយចុានឃើញផ្លែសំគមមួយដែលចូលទៅកុងព្រៃនោះដែរ ផ្លែនេះ គឺជាផ្លែព្រៃកំសត់ចាស់ជរារោមរុះគ្មានសល់ កមរមាស់ពេញខ្ជូន៍ ដែលល្ជូចចូលទៅកុងទីក្រុងកុងវេលាថ្ងៃ ដើម្បីរកអាហារក្រៀមក្រោះ ដែលអ្នកស្រុកចុោះចោលកុងសំរាមតាមផ្ជូវ ។ ជល់ពេលព្រលប់ដោយខ្ជាចគេវាយ រាកឹរត់ទៅកាន់ព្រៃដែលជ្ជាប់នៅ ។

អាហ៍មនដា (Ahmanda) ភ្លេចគិតដល់ពាក្យទូន្មានព្រះពុទ្ធក៏កាន់ដំបងមួយយ៉ាងធំនៅដៃ រត់ដេញតាមឆ្កែនោះទៅ ដោយឥតពិចារណាបន្តិចសោះ ៗ ឯឆ្កែនោះភ័យតក់ស្លុតនឹងការប្រហារនេះ ក៏ឈប់រត់ហើយនិយាយថា "ឱព្រាហ្មណ៍! បើលោកសំឡាប់ខ្ញុំ តើលោកបានផលប្រយោជន៍អ្វី? ខ្ញុំសុំចិត្តលោក សុំលោកកុំសំឡាប់ខ្ញុំធ្វើអ្វី ហើយខ្ញុំសុំសន្យាថា ខ្ញុំនឹងជូនមាស ២ ពាន់ត្រណោតដល់លោក" ៗ ឯព្រាហ្មណ៍ភ្លេចគិតដល់សាសនាព្រះពុទ្ធបែរចិត្តទៅរកគ្រឿងតំរេក ភ្លេចដល់សេចក្តីអំនួតដ៏អាក្រក់ នៅនាលោកនេះ ក៏ឆ្លើយទៅឆ្កែវិញថា: "ល្អណាស់ អញសុខចិត្ត អញមិនសំឡាប់ឯងទេ ប៉ុន្តែឯងត្រូវឲ្យរបស់ដែលឯងសន្យានោះមកអញឲ្យឆាប់" ៗ "ឱព្រាហ្មណ៍! តើឲ្យខ្ញុំជូនមាសនោះមកលោកនៅទីនេះម្តេចបាន? ខ្ញុំឥតជាប់មកជាមួយផងទេ; បើដូច្នោះ អ្នកចូរបើខ្ញុំទៅឯកន្លែងដែលខ្ញុំធ្លាប់នៅក្នុងព្រៃឯណោះទើបបាន គឺនៅព្រៃឯណោះទេដែលខ្ញុំលាក់កំណប់របស់ខ្ញុំ, លុះកាលណាទៅដល់ហើយ ខ្ញុំនឹងទៅយកមកជូនលោកភ្លាមឲ្យគ្រប់ចំនួន ៗ ព្រាហ្មណ៍ថា "នែបងឆ្កែ បើអញបើសត្តិរប្លានដូចឯងនេះ តើអ្នកដំណើរផងទាំងពួងគេនិន្ទាអញយ៉ាងណាទៅ?" ៗ ឆ្កែថា "-បើដូច្នោះ រុំខ្ញុំក្នុងអាវរបស់លោក រួចលើកលីខ្ញុំលើស្មាទៅ បើអ្នកណាមើលឃើញ ទៀងតែពឹកស្មានថា លោកលីកូនឬចៅរបស់លោកមិនខាន" ៗ ឯព្រាហ្មណ៍ដោយមានចិត្តលោភចង់

ឃ្លានមាស ២ ពាន់ត្រណោត ដែលគាត់ឃើញនៅក្នុងកណ្តាប់ដៃគាត់នៅ
ហើយ ក៏ត្រមង្រៀងធ្វើតាមពាក្យផ្ទៃបង្ហាប់ គាត់រុំផ្ទៃនោះក្នុងអាវរបស់
គាត់ហើយ ក៏លើកដាក់លើស្មារួចដើរត្រង់ទៅមុខ ដោយមានជំហាន
នោះវែង ។ ចូលទៅក្នុងព្រៃ ។

លុះទៅដល់កន្ទេងផ្ទៃដែលសំណាត់នោះ ។ ផ្ទៃក៏ឃ្លានប្រាប់ហើយ
ក៏និយាយទៅកាន់ព្រាហ្មណ៍ថា: "នែទៅហ្ការយម្ចាស់ នៅចាំខ្ញុំត្រង់កន្ទេង
នេះមួយស្របត់សិន ខ្ញុំទៅយកមាស ២ ពាន់ត្រណោត រួចខ្ញុំយកមក
ជូនលោកភ្លាម ដើម្បីជារង្វាន់ដល់លោក ដោយលោកមានចិត្តល្អនឹងខ្ញុំ"
ថាហើយផ្ទៃនោះ ក៏ប្រាលចូលទៅក្នុងព្រៃជ្រៅយ៉ាងហ៊ាសដោយឥតដាក
ក្រោយបន្ទិចឡើយ ។

ឯព្រាហ្មណ៍ក៏រង់ចាំនៅកន្ទេងនោះគ្រាលតែយប់ ឥតមានឃើញផ្ទៃ
នោះត្រឡប់មកវិញសោះ ។ រួចគាត់ក៏ប្រុះដេកទៅលើពស្ត្រ នៅ
ត្រង់កន្ទេងនោះអស់ ១ យប់ លុះព្រឹកឡើង ក៏មិនឃើញផ្ទៃនោះមក; .
គាត់ក៏រង់ចាំទៅទៀត លុះត្រាតែដល់ព្រឹកស្អែក ដោយឥតបានផលអ្វី
សោះ ។

ក្រោយមក មានអ្នកដំណើរម្នាក់ដើរតាមផ្លូវនោះ លុះបានឃើញ
ព្រាហ្មណ៍ឈរស្ងៀមក្ដុតចាលផ្ទាប់ទៅត្រង់កន្ទេងដែលផ្ទៃដើរចេញទៅ
នោះ ក៏សាកសួរទៅព្រាហ្មណ៍ថា តើអ្នករង់ចាំអ្វី ។ ព្រាហ្មណ៍ក៏និយាយ

ប្រាប់រឿងហេតុទាំងអស់ អំពីហេតុដែលគាត់ខានសំឡាប់ឆ្កែនោះ និង អំពីមាស ៦ ពាន់ត្រណោតដែលឆ្កែបានសន្យាថាឲ្យ ។ ឯអ្នកដំណើរនោះ និយាយដោយទ្រគោះថា: "អ្នកឯងឆ្លួតជាងឆ្កែនោះទៅទៀត, ហេតុម្តេចបានជាអ្នកឯងធាប់ជឿពាក្យរបស់ឆ្កែតិរច្ឆានដែលមិនចេះរកកំទេចអាហារខ្លួនឯងបានផងនោះ? ឯកិច្ចដ៏ប្រសើរដែលអ្នកត្រូវធ្វើ គឺអ្នកត្រឡប់ទៅផ្ទះវិញ ហើយចូរអ្នកកុំអួតអាងថាគ្រាន់បើ!" ។

ព្រាហ្មណ៍ក៏សុខចិត្ត ប្រព្រឹត្តតាមដំបូន្មានដ៏ប្រសើរនេះដោយអៀនខ្មាសផង ប៉ុន្តែដោយបានជាស្ឃើយអំពីកំហុសរបស់ខ្លួនហើយបានធ្វើតាមដំបូន្មានអ្នកប្រាជ្ញ ធូដាម្មាសារី (Thou damma Sari) ដែលគេតែងនិយាយមិនដែលឈប់ថា:

"មនុស្សណា ដែលចង់បាននាមឲ្យពេញជាមនុស្សធ្នាត គោងប្រុងប្រយ័ត្ន កុំទុកចិត្តមនុស្សដែលមិនសម, មុននឹងទុកចិត្តអ្នកណាមួយគោងថ្វឹងឲ្យស្អិត រួចគោងគិតមើលដំឡៃពិតនៃការសម្ងាត់ ដែលអ្នកត្រូវជ្រើស, បើមិនដូច្នោះទេ អ្នកនឹងធ្វាក់ខ្លួនដូចព្រាហ្មណ៍នេះ ដែលសត្វឆ្កែកំសត់ បានលូកលេងហើយបានទាំងបំបែរឲ្យទៅជាល្ឃេងសើចផង,

(មានត)

ពុទ្ធសាសនា ចំនិ ពាហ៉ាសាសនា

លោកមុិញ - ន៉ាគ្រី តំណាងរាស្ត្រ រៀបរៀង

អាទិកថា

ដំណើរដើមដែលនាំឲ្យកើតជាសៀវភៅនេះឡើង ដោយហេតុដែលខ្ញុំបានទៅធ្វើមេប្រយោគប្រឡងសិស្សចេញពីសាលាបាលីរងរៀងរាល់ឆ្នាំ ហើយច្រើនត្រូវមុខសួរអំពីរឿងសាសនាបំពោះសិស្សទាំងឡាយ ។ ពេលដែលសួរម្តង ៗ អ្នកប្រឡងច្រើនតែទើសទាល់ ធ្វើយមិនសូវបានហូរហែទូលាយសេចក្តីងាយស្តាប់សោះ ។ រឿងនេះជាហេតុនាំឲ្យខ្ញុំនឹកគួចទុកក្នុងចិត្តថាឱ្យណាមួយនឹងធ្វើសៀវភៅនេះឲ្យកើតឡើង ដើម្បីជាផ្ទូវងាយស្រួលសិក្សានៃពួកសិក្ខាកាម បំបាត់ការទទាក់ទទាមក្នុងរឿងនេះចេញ ។

ក្នុងការធ្វើសៀវភៅនេះ ប៉ែកខាងពុទ្ធសាសនាខ្ញុំស្រង់មកអំពីគម្ពីរបឋមសាមន្តបាសាទិកា ព្រមទាំងន័យជទៃទៀតខ្ចះ, ចំណែកខាងពាហ៉ាសាសនា, ខ្ញុំបានជកស្រង់មកអំពីច្បាប់ផ្សង ៗ ជាភាសាបាលីខ្ចះ, បារាំងខ្ចះ, សៀមខ្ចះ រួបរួមគ្នាកើតជាសៀវភៅនេះឡើង ។

លុះរៀបរៀងចប់ហើយ ខ្ញុំបានយកទៅជូនពុទ្ធសាសនបណ្ឌិត្យឲ្យជួយបោះពុម្ពផ្សាយ ដើម្បីជាវិជ្ជាសម្បត្តិសំរាប់សិស្សសាលាបាលីផង

សំរាប់សាធារណជនទូទៅផង លោកអគ្គលេខាធិការនៃពុទ្ធសាសន-
បណ្ឌិត្យក៏បានទទួលដោយសេចក្តីសោមនស្ស ។

ខ្ញុំសូមអភ័យទោសអំពីពួកបណ្ឌិតជនសូមកុំឲ្យយល់ថា ខ្ជូនខ្ញុំអ្នករៀប
រៀងលំអៀងទៅតាមអគតិណាមួយឡើយ គឺខ្ញុំតែងតាមលំអានដែលមាន
មកហើយស្រាប់តាមច្បាប់នោះ។ បើមានសេចក្តីឃ្វៀងឃ្វាតត្រង់ណា
សូមមេត្តាបំពេញឲ្យទានផង ។

ទីបំផុតនេះ, សូមទ្ធិសកុសលដែលកើតអំពីសៀវភៅនេះ ជូនទៅ
បុព្វការីជនទាំងឡាយ នឹងចែកវំលែកជល់សព្វសត្តនិករទូទៅ សូមឲ្យ
បានសេចក្តីសុខសំរាន្តសព្វ ៗ កាល ។

សព្វេ សត្តា អវេរា ហោន្តុ

សូមឲ្យសត្វរាល់គ្នា កុំបីមានពៀរនឹងគ្នាឡើយ

វត្តទណ្ណាលោម ក្រុងភ្នំពេញ

ថ្ងៃព្រហស្សតិ ១៦ កើតខែមិគសិរ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៦

(ថ្ងៃ ៥ ខែធេសមប្រឹ ឆ្នាំ ១៩៤៣)

ម ដ៉ាគ្រី

ពុទ្ធសាសនា

ពាក្យថា សាសនា

ពាក្យឆ្លាត ពាក្យទូន្មានប្រៀនប្រដៅរបស់សាស្តាចារ្យណាមួយក្នុងលោក ហៅថា សាសនា ។

សាសនាបើសំដែងដោយប្រភេទជាប្រធាននៃគោលធំ ៗ មាន ២ គឺ ពុទ្ធសាសនា ១ ពាហិរសាសនា ១ ។

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអគ្គបុគ្គល ជាសាស្តាឯកក្នុងលោក ហៅថា ពុទ្ធសាសនា ។ ពាក្យប្រៀនប្រដៅរបស់គណាចារ្យណាមួយដទៃក្រៅចាកព្រះបរមសាស្តា ហៅថា ពាហិរសាសនា ។

ពុទ្ធសាសនាប្រដៅឲ្យជ្បឹហេតុនឹងផល គឺឲ្យអាងឲ្យប្រកាន់ថាហេតុល្អនឹងឲ្យផលល្អ ហេតុអាក្រក់នឹងឲ្យផលអាក្រក់ អ្វីទាំងអស់ក្នុងលោកសុទ្ធសឹងប្រកបដោយហេតុនឹងផល សមដូចជាគាថាដែលព្រះអស្សជិត្ថេរសំដែងអាងឡើងថា :

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ ឧរោធោ ច ឯវំ វាទី មហាសមណោ

ព្រះតថាគត ទ្រង់ត្រាស់សំដែងនូវធម្មិទាំងឡាយ ដែលជាធម្មិមានហេតុជាដែនកើតមុន ទ្រង់ត្រាស់សំដែងនូវសេចក្តីរលត់នឹងទុបាយ

នៃសេចក្តីរលត់នូវធម៌ទាំងឡាយនោះ ព្រះមហាសមណៈទ្រង់មានប្រក្រតីពោលយ៉ាងនេះ ។

មួយទៀត ពុទ្ធសាសនាប្រដៅឲ្យដឿកម្មនឹងផលរបស់កម្ម គឺថាកម្មល្អនឹងឲ្យផលល្អ កម្មអាក្រក់នឹងឲ្យផលអាក្រក់; សេចក្តីល្អ អាក្រក់សុខទុក្ខ ចំរើនវិនាស មានក្រជាដើម ស្រេចហើយតែអំពើរបស់ខ្លួនដែលបានធ្វើទុកក្នុងអតីតជាតិ ឬក្នុងជាតិជាបច្ចុប្បន្ន ឥតមានអ្វីជួយឲ្យកន្ធងផុតចាកកម្មនឹងផលនៃកម្មទៅបានឡើយ ។

សមដូចព្រះពុទ្ធដីកាសំដែងទុកក្នុងទសធម្មសូត្រថា **កម្មស្ស**
កោម្ហិ អាត្មាអញមានកម្មជារបស់ខ្លួន **កម្មទាយាទោ** មានកម្មជាទ្រព្យសំបាច់មតិក **កម្មយោនី** មានកម្មជាកំណើត **កម្មពន្ធុ** មានកម្មជាផៅពង្សជាសាច់សន្តាន **កម្មបដិសរណោ** មានកម្មជាទីពឹងអាស្រ័យ **យំ កម្មំ ករិស្សាមិ កល្យាណំ វា ចាបកំ វា** អាត្មាអញនឹងធ្វើនូវអំពើឯណា ទោះជាអំពើល្អក្តី អាក្រក់ក្តី **តស្ស**
ទាយាទោ ភវិស្សាមិ នឹងបានជាអ្នកទទួលយកផលកម្មនោះប្រាកដពុំខាន ។

ន័យមួយទៀតថា:

អត្តនា វ កតំ ចាបំ អត្តនា សំកិលិស្សតិ
អត្តនា អកតំ ចាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ

អំពើអាក្រក់ដែលខ្លួនឯងធ្វើហើយ នឹងសៅហ្មងដោយខ្លួនឯង អំពើអាក្រក់ដែលខ្លួនមិនបានធ្វើហើយ នឹងបរិសុទ្ធចំពោះខ្លួន សេចក្តីបរិសុទ្ធ មិនបរិសុទ្ធ សេចលើខ្លួន បុគ្គលដទៃនឹងឲ្យបុគ្គលដទៃបរិសុទ្ធដូចម្តេចបាន ។

គោលប្រដៅ ៣ យ៉ាង

ពុទ្ធសាសនា បើសំដែងអំពីគោលនៃការប្រដៅធំ ៗ មាន ៣ គឺ:

១- សព្វមាបស្ស អការណំ កិរិយាមិនធ្វើអំពើអាក្រក់សព្វយ៉ាង ។

២- ការលស្ស្ឋូបសម្ឋដា ការញ៉ាំងកុសលឲ្យសំរេចគឺឲ្យទំធ្វើអំពើល្អ ។

៣- សចិត្តបរិយោដបនំ កិរិយាញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង់ គឺត្រូវដុសខាត់ចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ។

ឯតំ ពុទ្ធានសាសនំ ពាក្យទាំង ៣ យ៉ាងនេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្ក ។

ពុទ្ធោវាទទាំង ៣ ប្រការនេះ បើនឹងរាប់បញ្ចូលទៅក្នុងបិដកទាំង ៣ គ្រង់ពាក្យថា: "មិនឲ្យធ្វើបាបសព្វយ៉ាង" ចាត់ចូលក្នុងវិនយបិដក, ពាក្យថា "ឲ្យទំធ្វើអំពើល្អ" ចាត់ចូលក្នុងសុត្តន្តបិដក, ពាក្យថា "ទំសំអាតចិត្តរបស់ខ្លួនឲ្យផូរផង់" ចាត់ចូលក្នុងអភិធម្មបិដក ។

ប្រយោជន៍ក្នុងពុទ្ធសាសនា

ពុទ្ធសាសនា បើសំដែងអំពីផលប្រយោជន៍អំពីគុណបំណាច់ប្ចកម្រៃ
រង្វាន់ដែលពុទ្ធសាសនិកជនត្រូវបានព្រះពុទ្ធទ្រង់ប្រដៅបំបែរផ្ទូវជា ៣ គឺ:

១ – ទិដ្ឋធម្មិកត្ត = ប្រយោជន៍ក្នុងបច្ចុប្បន្ន

២ – សម្បរាយិកត្ត = ប្រយោជន៍ក្នុងលោកខាងមុខ

៣ – បរមត្ត = ប្រយោជន៍ដ៏ឧត្តមគឺព្រះនិព្វាន

ប្រយោជន៍បច្ចុប្បន្ន ចែកចេញជា ៤ ប្រការគឺ:

១ – **ឧដ្ឋានសម្បទា** សេចក្តីពេញលេញដោយការខ្នះខ្នែង
គឺការខំប្រឹងរកទ្រព្យសម្បត្តិ ឲ្យបានមកតាមធម៌ មានវ៉ៀរចាកចំនួញ
៥ ប្រការជាដើម ។

២ – **អារក្ខសម្បទា** សេចក្តីពេញលេញដោយការរក្សា
គឺការចេះរក្សាទ្រព្យសម្បត្តិដែលបានមកហើយ ឲ្យគង់នៅមិនឲ្យវិនាស
ទៅដោយល្បែងពាលផ្សេងៗ មានល្បែងស្រី-ស្រា-ស៊ីសងជាដើម ។

៣ – **កល្យាណមិត្តតា** ភាពនៃបុគ្គលមានមិត្តល្អ គឺវ៉ៀរ
ចាកបាបមិត្ត ហើយសេពគប់រាប់រកតែកល្យាណមិត្ត ។

៤ – **សមជីវិតា** ភាពនៃបុគ្គលអ្នកចិញ្ចឹមជីវិតស្មើៗ គឺចិញ្ចឹម
តាមសមគួរដល់កំឡាំងធនធានរបស់ខ្លួន មិនចាយវាយខ្ជះខ្ជាយឥតបទ
ឥតសណ្តាប់ ។

នេះជាប្រយោជន៍សំម្រាប់ចែកសេចក្តីសុខក្នុងបច្ចុប្បន្ន ។

ប្រយោជន៍ក្នុងលោកខាងមុខ ចែកចេញជា ៦ ប្រការ គឺ:

១ – សទ្ធាសម្បទា សេចក្តីពេញលេញដោយជំនឿ

២ – សីលសម្បទា សេចក្តីពេញលេញដោយសីល គឺត្រូវ
រក្សានិច្ចសីល ឧបោសថសីល អតិរេកសីល ចតុប្បារិសុទ្ធិសីល តាម
នាទីរបស់ខ្លួន ។

៣ – ចាគសម្បទា សេចក្តីពេញលេញដោយការចែកទាន
គឺចេះចែកវំលែកធនធានដែលខ្លួនរកបានមកដោយធម៌ ជល់សមណ:
ព្រាហ្មណ៍ យាចកអ្នកកំសត់ទុគិត កំព្រីកំព្រា អនាថា តាមសមគួរ ឈ្មោះ
ថាជាគ្រឿងចែកសេចក្តីសុខជល់អ្នកដទៃ ។

៦ – ចញ្ញាសម្បទា សេចក្តីពេញលេញដោយបញ្ញា គឺ
ប្រកបដោយសេចក្តីយល់ឃើញជាសម្មាទិដ្ឋី មានការយល់ឃើញថាធ្វើ
បុណ្យបានបុណ្យធ្វើបាបបានបាបជាដើម ។

ប្រភេទរបស់ព្រះពុទ្ធសាសនា

ពុទ្ធវចន:ទាំងអស់នោះ គឺ:

រសវសេន ឯកវិធំ មានតែមួយដោយអំណាចនៃវិមុត្តិរស

ធម្មវិនយវសេន ទុវិធំ មាន ៦ យ៉ាងដោយអំណាចនៃធម៌
នឹងវិន័យ

បឋមមជ្ឈិមបច្ឆិមវសេន តិវិធំ មាន ៣ យ៉ាងដោយបឋម-ពុទ្ធវចន: មជ្ឈិមពុទ្ធវចន: និងបច្ឆិមពុទ្ធវចន: ។

ឆថា បិដកវសេន មាន ៣ យ៉ាងដោយអំណាចបិដកទាំង ៣

និកាយវសេន បញ្ចវិធំ មាន ៥ យ៉ាងដោយអំណាចនៃនិកាយទាំង ៥

អង្គវសេន នវវិធំ មាន ៩ យ៉ាងដោយអំណាចនៃអង្គទាំង ៩

ធម្មក្ខន្ធវសេន ចតុរាសីតិសហស្សវិធំ មាន ៨៤.០០០ ដោយអំណាចព្រះធម្មក្ខន្ធ ។

ពុទ្ធវចន: ១ យ៉ាង

ពាក្យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រៀនប្រដៅសត្វលោកមានទេពតាមនុស្សនាគយក្ខធាដើម ឬធម៌ដែលទ្រង់រំពឹងពិចារណាក្នុងរវាង ៤០ វស្សា ចាប់ដើមអំពីថ្ងៃដែលទ្រង់ឲានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដរាបដល់ពេលដែលទ្រង់រំលត់ខន្ធចូលកាន់បរិនិព្វានដោយអនុឲាទិសេសនិព្វានធាតុ ព្រះពុទ្ធវចន: ទាំងអស់នុ+ះប្រមូលរួបរួមមកមានតែមួយ គឺដើម្បីឲ្យសត្វឲានក្រេបផឹកនូវវិមុត្តិរសប៉ុណ្ណោះឯង; យ៉ាងនេះឈ្មោះថា ពុទ្ធវចន: មានតែមួយដោយអំណាចនៃវិមុត្តិរស ។

ពុទ្ធវចន: ២ យ៉ាង

សព្វមេវ ពេតំ ឧម្មោ ច វិនយោ ច ក៏ឯពុទ្ធវចន: ទាំងអស់ហ្នឹងឯង រួបរួមមកមានពីរយ៉ាង គឺធម៌ ១ វិន័យ ១ ។

តន្តិ វិនយបិដកំ វិនយោ បណ្ដាពុទ្ធវចនៈទាំង ២ នោះ វិនយបិដក ហៅថា វិន័យ, អវសេសំ ពុទ្ធវចនំ ធម្មោ ពុទ្ធវចនៈដ៏សេស ក្រៅពីវិន័យ ហៅថា ធម៌ ។

សមដូចពាក្យដែលព្រះមហាកស្សបត្ថេរពោលទុកថា យន្នូន មយំ អាវុសោ ធម្មញ្ច វិនយញ្ច សង្គាយាម ម្នាលអាវុសោ បើដូច្នោះ មានតែយើងនឹងសង្គាយនានូវធម៌ផង វិន័យផង ខ្ញុំត្រូវសួរវិន័យចំពោះឧបាលី, ត្រូវសួរធម៌ ចំពោះអានន្ទ; យ៉ាងនេះ ដែលឈ្មោះថា ពុទ្ធវចនៈមាន ២ យ៉ាងដោយអំណាចធម៌នឹងវិន័យ ។

ពុទ្ធវចនៈ ៣ យ៉ាង

សព្វមេវ ចិទំ បឋមពុទ្ធវចនំ មជ្ឈិមពុទ្ធវចនំ បច្ឆិមពុទ្ធវចនន្តិ តប្បភេទំ ពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ៣ គឺ: បឋមពុទ្ធវចនៈ ១ មជ្ឈិមពុទ្ធវចនៈ ១ បច្ឆិមពុទ្ធវចនៈ ១ ។

បណ្ដាពុទ្ធវចនៈទាំង ៣ នេះ ត្រង់ឧទានគាថាដែលព្រះសាស្ដាទ្រង់នឹកក្នុងអស្សារម្យក្នុងព្រះទ័យលាន់ចេញមកជាព្រះវាចា ក្នុងកាលដែលទើបបានត្រាស់ដឹងថ្មីៗ ថា :

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ

សព្វា ទេ ជាសុតា ភិក្ខា ឥហ ភិក្ខូ ! ទ្វិសន្ធិ
ទ្វិសន្ធ្យារកត់ ចិត្តំ តណ្ហាន ១ យមជ្ឈគា ។

តថាគតកាលអង្គាសទៅមក យោនយកកំណើតក្នុងសង្សារវដ្ត
អស់ជាតិជាអនេកស្វែងរកជាងផ្ទះគឺតណ្ហា មិនទាន់ជួបប្រទះនៅឡើយ
ម្ល៉ះហើយជាតិតែងនាំមកនូវសេចក្តីទុក្ខលំបាកវៀយ។, នែជាងផ្ទះ តថា-
គតរកអ្នកឃើញហើយ អ្នកលែងសង់ផ្ទះគឺអត្តភាពឲ្យតថាគតទៀតហើយ
(ព្រោះថា) ត្រឿងប្រក់របស់អ្នកតថាគតបាត់ភេចបំបាក់ចោលអស់លង
ហើយ ទាងកំពូលផ្ទះតថាគតកាច់ចោលហើយដែរ ចិត្ត (របស់តថាគត)
ផុតស្រឡះចាកការតាក់តែងហើយ ព្រោះតថាគតបានដល់នូវការអស
ទៅនៃតណ្ហា, នេះហៅថា បឋមពុទ្ធវចនៈ ។

ពុទ្ធវចនៈដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ធ្លាប់ធុតក្នុងកាលទៀប
បរិនិព្វានជាអាសានុភាពថា: ហន្ទ ទានិ ភិក្ខវ: អាមន្តយាមិ ភេ
វយធម្មា សង្ខារា អប្ប្រមាទេន សម្ប្ប:ទេថ នែភិក្ខុទាំងឡាយ
ឥឡូវនេះតថាគតធ្លាប់អ្នកពាល់ គ្នាថា: "សង្ខារទាំងឡាយរមែងមានសភាព
សោះសូន្យទៅជាធម្មតា (ហេតុនេះ) អ្នកពាល់ គ្នា ចូរញ៉ាំងកិច្ចទាំងពួងឲ្យ
សំរេច ដោយសេចក្តីមិនប្រហែសធ្វេស", នេះហៅថា ឧត្តមពុទ្ធវចនៈ ។

ពុទ្ធវចនៈទាំងអស់ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងក្នុង
កាលជាច្រើន ជាកណ្តាលនៃពុទ្ធវចនៈទាំងពីរ គឺបឋមពុទ្ធវចនៈនិង
ឧត្តមពុទ្ធវចនៈ ហៅថា មជ្ឈិមពុទ្ធវចនៈ ។

យ៉ាងនេះដែលហៅថាពុទ្ធវចនៈមាន ៣ យ៉ាង ដោយអំណាចពុទ្ធវចនៈជាន់ដំបូង ជាន់កណ្តាល ជាន់ចុងបំផុត ។

ពុទ្ធវចនៈ ៣ យ៉ាង ២ដក ៣

ពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ៣ គឺវិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។

បណ្តាពុទ្ធវចនៈទាំង ៣ នោះ ឫជាដំមោក្ខទាំង ២ (ភិក្ខុឫជាដំមោក្ខ ភិក្ខុនីឫជាដំមោក្ខ) វិភង្គទាំង ២ (ភិក្ខុវិភង្គ ភិក្ខុនីវិភង្គ) ១ខន្ធក ២២ បរិវារ ១ ដែលលោកប្រមូលយកសង្ខ្លីតនឹងអនុសង្ខ្លីតទាំងអស់ ក្នុងកាលបឋមសង្គាយនា បើតិតរួមមកជាគម្ពីរមាន ៥ គឺ: ភាវិកម្ម, ឫជាបិត្តិយ, មហាវគ្គ ចុល្លវគ្គ, បរិវារ, រួមមកហៅថា វិនយបិដក ។

ធម្មដែលលោករួបរួមយកសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើមមកឲ្យឈ្មោះថា "ទីឃនិកាយ" ។ ធម្មដែលលោករួបរួមយកសូត្រ ១៥២ មានមូលបរិយាយសូត្រជាដើមមកឲ្យឈ្មោះថា "មជ្ឈិមនិកាយ" ។ ធម្មដែលលោករួបរួមយកសូត្រ ៧៧៦២ មានឆយតនៈសូត្រជាដើមមកឲ្យឈ្មោះថា "សំយុត្តនិកាយ" ។ ធម្មដែលលោករួបរួមយកសូត្រ ៩៥៥៧ មកឲ្យឈ្មោះថា "អង្គុត្តរនិកាយ" ។ ធម្មដែលមានប្រភេទ ១៥ គឺខុទ្ទកបាឋ, ធម្មបទ, ឧទាន, តតិវុត្តក, សុត្តនិបាត, វិមានវត្ថុ, បេតវត្ថុ, ថេរគាថា, ថេរីគាថា, ជាតក, និទ្ទេស, បដិសម្ភិទា, អបទាន, ពុទ្ធវង្ស, ចរិយាបិដក, មកឲ្យឈ្មោះថា "ខុទ្ទកនិកាយ" ។

ធម្មសង្គណី, វិភង្គ, ធាតុកថា, បុគ្គលប្បញ្ញត្តិ, កថាវត្ថុ, យមក, បដ្ឋាន ហៅថា "អភិធម្មបិដក" ។

បិដកទាំង ៣ នេះ បើចែកតាមដំណើរទេសនាមាន ៣ គឺ អាណាទេសនា ១ វោហារទេសនា ១ បរមត្ថទេសនា ១ ។

វិនយបិដក ដែលព្រះដ៏មានព្រះភាគជាបុគ្គលគួរដល់អាជ្ញា ត្រាស់សំដែងសម្បូណ៌ដោយអាជ្ញា ហៅថា "អាណាទេសនា" ។ សុត្តន្តបិដក ដែលព្រះដ៏មានព្រះភាគជាវោហារកោសល គឺជាបុគ្គលឈ្លាសវៃដោយវោហារទ្រង់ព្រះទស្ស ត្រាស់សំដែងសម្បូណ៌ដោយវោហារ ហៅថា "វោហារទេសនា" ។ អភិធម្មបិដក ដែលព្រះដ៏មានព្រះភាគឈ្លាសវៃដោយបរមត្ថ ត្រាស់សំដែងច្រើនដោយបរមត្ថធម៌ ជាធម៌មានសេចក្ដីជាលើ ហៅថា "បរមត្ថទេសនា" ។

ចែកតាមដំណើរពាក្យសាសនា (ការប្រៀនប្រដៅ) មាន ៣ យ៉ាងគឺ យថាបរាធសាសនា ១ យថានុលោមសាសនា ១ យថាធម្មសាសនា ១ ។

វិនយបិដក ហៅថា យថាបរាធសាសនា (ការប្រៀនប្រដៅតាមកំហុស) ព្រោះថាពួកសត្វដែលមានកំហុស ព្រះអង្គទ្រង់ប្រៀនប្រដៅតាមកំហុស ក្នុងវិនយបិដកនេះ ។ សុត្តន្តបិដក ហៅថា យថានុលោមសាសនា (ការប្រៀនប្រដៅតាមសមគួរ) ព្រោះថាពួកសត្វដែលលង់នៅក្នុងអធ្យាស្រ័យ អនុស័យនិងចរិយាជាអនេក ព្រះអង្គត្រាស់ប្រៀនប្រដៅ

អម្ចុសោមតាមអធ្យាស្រ័យ អនុស័យនឹងចរិយានោះ។ ក្នុងសុត្តន្តបិដកនេះ ។ អភិធម្មបិដក ហៅថា យថាធម្មសាសនា (ការប្រែនប្រែជាតាមធម្មិឬតាមសភាពពិតមែន) ព្រោះថា ពួកសត្វដែលមានសេចក្តីយល់ក្នុងពួកនៃធម្មិថា "ខ្ញុំអញ របស់អញ" ព្រះអង្គទ្រង់សំដែងប្រែនប្រែជាតាមសភាពពិត ក្នុងអភិធម្មបិដកនេះ ។

បើចែកតាម កថា មាន ៣ យ៉ាង គឺ: សំវាសំវាកថា ១ ទិដ្ឋិនិវេ-ឋនកថា ១ នាមរូបបរិច្ឆេទកថា ១ ។

វិនយបិដក ហៅថា សំវាសំវាកថា ព្រោះការសង្ហ្ម៖ទ្ធ៖ មិនសង្ហ្ម៖ជាសត្រូវដល់អធ្យាចារ (សេចក្តីប្រព្រឹត្តិល្អ្ហ៖ត្រូវ) ព្រះអង្គទ្រង់សំដែងទុកក្នុងវិនយបិដកនេះ ។ សុត្តន្តបិដក ហៅថា ទិដ្ឋិនិវេឋនកថា ព្រោះថាការដោះចាកទិដ្ឋិ ជាបំភ្លឺពួកនៃទិដ្ឋិ ៦២ ព្រះអង្គទ្រង់ត្រាស់សំ-ដែងទុកក្នុងសុត្តន្តបិដកនេះ ។ អភិធម្មបិដក ហៅថា នាមរូបបរិច្ឆេទកថា ព្រោះការកំណត់ន្ទូវនាមនឹងរូប ជាសត្រូវដល់កិលេសមានរាគៈជាដើម ព្រះអង្គទ្រង់សំដែងទុកក្នុងអភិធម្មបិដកនេះ ។

បិដកទាំង ៣ នេះ បើចែកតាមសិក្ខា មាន ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្ញ្ញាសិក្ខា ១ ។ វិនយបិដកគាប់ចាប់ក្នុងអធិសីល-សិក្ខា ពីព្រោះការសិក្សាការរៀនយកអធិសីល ព្រះអង្គទ្រង់សំដែងទុក

ដោយសេចក្តីពិសេសពិស្តារក្នុងវិនយបិដក ។ សុត្តន្តបិដក ពាក់បញ្ជូលក្នុងអធិចិត្តសិក្ខា ព្រោះចាការសិក្សារៀនយកអធិចិត្ត ព្រះអង្គត្រាស់សំដែងទុកក្នុងសុត្តន្តបិដក ។ អភិធម្មបិដក ពាក់បញ្ជូលក្នុងអធិប្បញ្ញាសិក្ខា ព្រោះថាការសិក្សារៀនយកអធិបញ្ញា ព្រះអង្គត្រាស់សំដែងដោយសេចក្តីវិសេសក្នុងអភិធម្មបិដក ។

បើចែកតាមប្រភេទនៃការលះ មាន ៣ គឺ វិតិក្កមប្បហាន ១ បរិយុដ្ឋានប្បហាន ១ អនុសយប្បហាន ១ ។

វិតិក្កមប្បហាន (ការលះបង់នូវសេចក្តីល្មើស) ពាក់បញ្ជូលក្នុងវិនយ-បិដក ព្រោះស៊ីលមានការប្រតិបត្តិកន្ទ្ធ ប្រតិបត្តិល្មើសជាសត្រូវ ។ បរិយុដ្ឋានប្បហាន (ការលះបង់នូវទីតាំងរបស់កិលេស) ពាក់បញ្ជូលក្នុងសុត្តន្តបិដក ព្រោះសមាធិមានបរិយុដ្ឋានក្តិលេសជាសត្រូវ ។ អនុសយ-ប្បហាន (ការលះបង់នូវអនុសយក្តិលេស) ពាក់បញ្ជូលក្នុងអភិធម្មបិដក ព្រោះបញ្ញាមានអនុសយ គឺធម្មជាតិគ្រឿងដេកតាំងក្នុងសន្តានជាសត្រូវ ។ ម្យ៉ាងទៀត ឥទ្ធិប្បហាន (ការលះបង់នូវអង្គដោយអង្គ) ពាក់បញ្ជូលក្នុងវិនយបិដក ។ វិក្ខម្ភនប្បហាន (ការលះបង់នូវកិលេសដោយការសង្កត់សង្កិន) និង សមុច្ឆេទប្បហាន (ការលះបង់ផ្តាច់ផ្តិល) ពាក់បញ្ជូលក្នុង សុត្តន្តបិដកនិងអភិធម្មបិដក ។

មួយទៀត ការលះបង់ទ្រព្យតូចតិចសង្ខ្លិសេស ពាក្យបញ្ជាក្នុងវិនយ-
បិដក, តណ្ហាសង្ខ្លិសេសនឹងទិដ្ឋិសង្ខ្លិសេស ពាក្យបញ្ជាក្នុងសុត្តន្តបិដក
នឹងអភិធម្មបិដក ។

ក្នុងបិដកមួយៗ មានគម្ពីរភាគជាច្រើន គឺភាពជ្រាលជ្រៅដោយធម្ម
ដោយអត្ថ ដោយទេសនា នឹងដោយបដិវេធ ។ ចាស់ ហៅថា ធម្ម,
សេចក្ដីអធិប្បាយរបស់ចាស់នោះ ហៅថា អត្ថ, ការសំដែងពន្យល់ទ្រ
ចាស់នោះ ហៅថា ទេសនា (ព្រោះចាស់ជាសត្ថុធាតុដែលបុគ្គលកំណត់
ទុកដោយចិត្ត), ការយល់ច្បាស់តាមសេចក្ដីពិតក្នុងចាស់នឹងសេចក្ដី
របស់ចាស់ ហៅថា បដិវេធ ។

បរិយត្តិមាន ៣ យ៉ាង គឺ អលគទូបរិយត្តិ ១ និត្ថរណបរិយត្តិ ១
តណ្ហាតារកបរិយត្តិ ១ ។

បណ្តាបរិយត្តិទាំង៣នេះ បរិយត្តិដែលបុគ្គលកាន់យកមិនល្អ គឺរៀន
ដើម្បីហេតុមានការប្រណាំងប្រជែងជាដើម ហៅថា អលគទូបរិយត្តិ
(បរិយត្តិប្រៀបដោយពស់មានពិស) មានសេចក្ដីប្រៀបដែលព្រះដ៏មាន
ព្រះភាគទ្រង់ត្រាស់ទុកថា: ម្នាលភិក្ខុទាំងឡាយ បុរសអ្នកត្រូវការដោយ
ពស់មានពិស ។ ល ។ បុរសនោះឃើញទ្រព្យពស់មានពិសយ៉ាងធំហើយ
ចាប់ទ្រព្យពស់ទ្ចុះ ត្រង់ព្ចនក្ដី ត្រង់កន្ទុយក្ដី ពស់នោះនឹងវាកត្រឡប់ចឹក
បុរសនោះត្រង់ដៃ ឬ ត្រង់ដើមដៃ ឬ ត្រង់អាយរ:ត្ចចធំណាមួយ បុរសនោះ

នឹងដល់នូវសេចក្តីស្ងាប់ ឬ នូវសេចក្តីទុក្ខទៀបស្ងាប់, ដំណើរនោះព្រោះ
ហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះតែពស់ដែលខ្លួនចាប់ហើយ
មិនល្អ មានឧបមាយ៉ាងណាមិញ; ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរស
ខ្ទះក្នុងលោកនេះរៀនយកនូវធម៌ ។ ល ។ មោឃបុរសនោះរៀននូវធម៌
នោះមិនចុានពិនិត្យនូវសេចក្តីរបស់ធម៌នោះដោយបញ្ញា ទាំងធម៌ទាំង
ឡាយនោះ ក៏មិនគួរដល់ការពិចារណាឃើញដល់ភិក្ខុទាំងឡាយនោះ
ដែលខ្លួនមិនពិចារណានូវសេចក្តីដោយបញ្ញា ភិក្ខុទាំងឡាយនោះមានតែ
អានិសង្សត្រឹមតែការប្រណាំងប្រជែងផង មានអានិសង្សត្រាន់តែរួចចាក
ពាក្យពោលថាដូច្នេះដូច្នោះផង រៀនយកនូវធម៌ ។ មួយទៀត ភិក្ខុទាំង-
ឡាយរៀនយកនូវធម៌ដើម្បីប្រយោជន៍ឯណា ក៏មិនចុានសំរេចប្រយោជន៍
នោះ ដល់ភិក្ខុទាំងឡាយនោះទេ; ធម៌ដែលភិក្ខុទាំងឡាយនោះរៀនហើយ
មិនល្អ រមែងប្រព្រឹត្តទៅព្រមដើម្បីមិនជាប្រយោជន៍ . នឹងសេចក្តីទុក្ខ
អស់កាលអង្វែង; ដំណើរនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះ
ភាពនៃធម៌ដែលភិក្ខុរៀនមិនល្អហើយ ។

ឯបរិយត្តិឯណា ដែលភិក្ខុកាន់យកល្អហើយ គឺដែលភិក្ខុរៀន
ដោយបំណងនឹងបំពេញនូវធម្មក្ខន្ធមានសីលក្ខន្ធជាដើម មិនមែនដើម្បី
ហេតុមានការប្រណាំងប្រជែងជាដើមឡើយ បរិយត្តិនេះ លោកហៅថា
និត្ថរណបរិយត្តិ ។

ពាក្យដែលព្រះដ៏មានព្រះភាគពោលទុកថា ធម៌ទាំងឡាយនោះ ដែលកិក្ខុទាំងឡាយនោះកាន់យកល្អហើយ រៀនល្អហើយ តែងប្រព្រឹត្ត ទៅព្រមដើម្បីប្រយោជន៍នឹងសេចក្តីសុខ អស់កាលជាអង្វែង; ដំណើរ នោះព្រោះហេតុអ្វី? ព្រោះថាធម៌ទាំងឡាយនោះ កិក្ខុរៀនយកល្អហើយ ។

ចំណែកឯព្រះខីណាស្រព ដែលមានខន្ធកំណត់ឋានហើយ មាន កិលេសលះបង់ហើយ មានមគ្គចំរើនហើយ មានអកុប្បធម៌ចាក់ផ្ទុះ ហើយ មាននិរោធធ្វើឲ្យជាក់ច្បាស់ហើយ លោករៀនយកនូវបរិយត្តិ ឯណា ដើម្បីប្រយោជន៍រក្សាប្រវេណី ដើម្បីប្រយោជន៍រក្សាវង្ស ប៉ុណ្ណោះ; បរិយត្តិនោះ ហៅថា កណ្ហាតារិកបរិយត្តិ ។

ពុទ្ធវចន: ៥ យ៉ាង

ពុទ្ធវចន:ទាំងអស់នោះ ចែកដោយនិកាយ មានប្រភេទ ៥ គឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

ព្រះសូត្រ ៣៤សូត្រ មានព្រហ្មជាលសូត្រជាដើម ដែលលោក រួបរួមទុកក្នុងវគ្គ ៣ ហៅថា ទីឃនិកាយ ព្រោះជាទីប្រជុំ ជាទី លំនៅនៃក្រុមសូត្រមានប្រមាណវែង ។

ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម ដែលលោករួបរួមទុកក្នុងវត្ត ១៥ មានប្រមាណ យ៉ាងកណ្ណាល (មិនវែងពេក មិនខ្លីពេក) ហៅថា មជ្ឈិមនិកាយ ។

ព្រះសូត្រ ៧៧៦២ សូត្រ មានឧយតរណសូត្រជាដើម ដែលតាំងនៅដោយអំណាចនៃធម៌មានទេវតាសំយុត្តជាដើម ហៅថា សំយុត្តនិកាយ ។

ព្រះសូត្រ ៩៥៥៧ សូត្រ មានចិត្តបរិយាយទានសូត្រជាដើម ដែលបិតនៅដោយអំណាចនៃអង្គមួយ ៗ ដ៏ក្រៃលែង ហៅថា អង្គុត្តរនិកាយ ។

ព្រះពុទ្ធវចន:ដ៏សេស ឥរិនយបិដក អភិធម្មបិដក ទាំងអស់ព្រមទាំងខុទ្ទកឡាប ដែលមានប្រភេទ ១៥ ដូចឡានសំដែងទុកហើយក្នុងខាងដើម លើកលែងតែនិកាយទាំង ៤ មានទីឃនិកាយជាដើមចេញ ហៅថា ខុទ្ទកនិកាយ ។

ព្រះពុទ្ធវចន:មាន ៥ យ៉ាងដោយអំណាចនិកាយ ៥ ដោយប្រការយ៉ាងនេះឯង ។

ពុទ្ធវចន: ៩ យ៉ាង

សព្វមេវ ហ៉ាធំ សុត្តំ គេយ្យំ វយ្យាការណំ គាថា ឧជានំ ឥតិវុត្តកំ ជាតកំ អព្ភូតធម្មំ វេទល្លន្តិ ឆវប្ឋកេធំ

ព្រះពុទ្ធវចនៈទាំងនោះមានប្រភេទ ៩ យ៉ាង គឺសុត្ត ១ គេយ្យ ១ វេយ្យាករណ ១ គាថា ១ ឧទាន ១ ឥតិវុត្តក ១ ជាតក ១ អព្ភូតធម្ម ១ វេទល្ប ១ ។

បណ្ណាសត្ថុសាសនៈទាំង ៩ ប្រការនោះ ចំណែកខាងឧកតោវិភង្ក (គឺកិក្ខុវិភង្ក កិក្ខុនីវិភង្ក) និទ្ទេស (ចូឡនិទ្ទេស មហានិទ្ទេស) ខន្ធក ៦៦ បរិវារ ១៦ ពួកសូត្រមានមង្គលសូត្រ រតនសូត្រ នាលកសូត្រ និងតុវដ្តកសូត្រជាដើមក្តី ពាក្យព្រះតថាគត ដែលបានតាមថាសូត្រ ដទៃក្តី ហៅថា សុត្ត ។

ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ គឺសូត្រដែលមានបាលីរាយលាយច្រឡំដោយគាថា ហៅថា គេយ្យ ។

អភិធម្មបិដកទាំងមូលនឹងសូត្រដែលឥតមានគាថា ឬក៏ពុទ្ធវចនៈដទៃដែលលោកមិនសង្រ្ទោះចូលដោយអង្គទាំង ៨ ហៅថា វេយ្យាករណៈ (ពាក្យបាលីរាយ) ។

ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធដែលមិនឲ្យឈ្មោះថា សុត្ត ក្នុងសុត្តនិបាត ហៅថា គាថា ។

ពួកព្រះសូត្រ ៦៦ ប្រកបដោយគាថាអាស្រ័យសោមនស្សញ្ញាណ ហៅថា ឧទាន ។

ក្រុមព្រះសូត្រ ១១០ ដែលប្រព្រឹត្តទៅដោយន័យថា "វុត្ថំ ហោតំ
កតវតា ពាក្យនេះពិតជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយ"
ហៅថា ឥតិវុត្តក ។

ជាតក ៥៥០ មានអបណ្ណកជាតកជាដើម ហៅថា ជាតក ។

ព្រះសូត្រប្រកបដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ដែលប្រព្រឹត្តទៅ
ដោយន័យមានដើមថា "ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភូត-
ធម្មា អានន្ទ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៤ យ៉ាងនេះ
អស្ចារ្យមិនធ្លាប់កើតមាន មាននៅក្នុងអានន្ទ" ហៅថា អព្ភូតធម៌ ។

ពួកសូត្រទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មា-
ទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ សង្ខារភាជនីយសូត្រ នឹងមហាបុណ្ណកសូត្រ
ជាដើម ដែលបុគ្គលបានសួរនឹងសេចក្តីត្រេកអរ៉ីករាយ សួរសាកដេញ
ដោលឡើង ហៅថា វេទល្ល ។

ព្រះពុទ្ធវចន:មាន ៩ ដោយអំណាចនៃអង្ក ៩ ដោយប្រការយ៉ាងនេះ ។

ពុទ្ធវចន: ៨៤.០០០

ព្រះពុទ្ធវចន:ទាំងអស់នោះ មានប្រភេទ ៨៤.០០០ ដោយអំណាចនៃ
ធម្មក្ខន្ធដែលលោកបំភ្លឺទុកយ៉ាងនេះថា:

ទ្វាសីតិ ពុទ្ធតោ កណ្ហឹ ទ្វេ សហស្សានិ ភិក្ខុនោ
ចតុរាសីតិសហស្សានិ យេ មេ ធម្មា បវត្តិនោ

ព្រះធម៌ឯណាដែលប្រព្រឹត្តទៅក្នុងហ្ហូទ័យនៃខ្ញុំ (ព្រះធម៌នោះ) មាន ៨៤.០០០ គឺព្រះធម៌ ៨៤.០០០ ខ្ញុំរៀនយកអំពីព្រះពុទ្ធ, ៦.០០០ រៀនអំពីកិត្ត ។

បណ្ណាធម្មក្ខន្ធទាំងឡាយនោះ ដែលនឹងកំណត់ដឹងថាជាធម្មក្ខន្ធមួយៗ គឺ ព្រះសូត្រ ដែលអនុសន្ធិតែមួយចាត់ជាធម្មក្ខន្ធ ១, ព្រះសូត្រណាមានអនុសន្ធិច្រើន ការរាប់ធម្មក្ខន្ធក្នុងព្រះសូត្រនោះ ក៏តាមអនុសន្ធិ (ច្រើនដែរ) ។

ក្នុងពួកគាថាពន្ធ លោកកំណត់ការសួរនូវប្រស្នាមួយ ចាត់ជាធម្មក្ខន្ធមួយ, ការវិស្សជ្ជនាមួយ ចាត់ជាធម្មក្ខន្ធមួយ ។

ក្នុងអភិធម្មវិញ្ញ លោកកំណត់ការចែកនូវតិក: ទុក:មួយៗ ឬការចែកនូវវារ:ចិត្តមួយៗ ចាត់ជាធម្មក្ខន្ធមួយ ។

ក្នុងវិន័យដែលមានវត្ថុ, មាតិកា, បទភាជនីយ, អន្តរាបត្តិ, អាបត្តិ, អនាបត្តិ នឹងការកំណត់នូវតិក:, ធម៌ទាំងនោះ ចំណែកមួយៗ ចាត់ជាធម្មក្ខន្ធមួយៗ ។

ក្នុងបិដកទាំង ៣ នេះ ព្រះសូត្រមាន ៦១.០០០ ព្រះធម្មក្ខន្ធ, ព្រះវិន័យមាន ៦១.០០០ ព្រះធម្មក្ខន្ធ, ព្រះអភិធម្ម មាន ៤៦.០០០ ព្រះធម្មក្ខន្ធ រួបរួមជា ៨៤.០០០ ព្រះធម្មក្ខន្ធ ។

ព្រះពុទ្ធវចន:មាន ៨៤.០០០ ដោយអំណាចនៃធម្មក្ខន្ធ ដោយប្រការយ៉ាងនេះ ។

បឋមសង្គាយនា

កាលព្រះបរមគ្រូអរហន្តសម្មាសម្ពុទ្ធ ទើបនឹងទ្រង់រំលត់ខ័ន្ធចូលកាន់បរិនិព្វានទៅបានរយៈ ៧ ថ្ងៃ ក៏គមានពាក្យបំរុងបម្រះគន្ថពុទ្ធ-សាសនមណ្ឌលជាហេតុនាំឲ្យពួកអរហន្តវល់ក្នុងកិច្ចសាសនា ទើបព្រះមហាកស្សបត្ថេរផ្ដួចផ្ដើមនាំព្រះអរហន្តទាំងឡាយលើកសង្គាយនា ផ្ទៀងផ្ទាត់ធម្មវិន័យលៃលកដាក់ទុកដោយពួក-ក្រមថានេះព្រះវិន័យ, នេះព្រះសូត្រ, នេះព្រះអភិធម្ម, សំរេចសេចក្ដីថា ធម៌ពិតធម៌មែន ។

កាលធ្វើសង្គាយនាលើកនេះ ព្រះមហាកស្សបជាអ្នកបុច្ឆាព្រះវិនយ-បិដក ចំពោះព្រះឧបាលី, បុច្ឆាព្រះសុត្តន្តបិដកនឹងព្រះអភិធម្មបិដកចំពោះព្រះអានន្ទ ព្រមដោយការកសង្ស សុទ្ធតែជាព្រះអរហន្តបដិសម្ភិទា ៥០០ អង្គ ធ្វើក្នុងសត្តបណ្ណគុហា ទៀបក្បែរការបពិតក្នុងនគររាជគ្រឹះ មានព្រះបាទអជាតសត្តុ ជាពុទ្ធសាសនូបត្ថម្ភក៍ អស់កាល ៧ ខែទើបសំរេច ។

ទុតិយសង្គាយនា

កាលព្រះអរហន្តទាំង ៥០០ អង្គ មានព្រះមហាកស្សបត្ថេរជាប្រធានបានធ្វើបឋមសង្គាយនារួចស្រេចហើយ ក៏គ្រប់គ្រងរក្សាព្រះពុទ្ធសាសនាតរៀងមកដរាបដល់អស់ព្រះជន្មបរិនិព្វានទៅរៀងព្រះអង្គ ៗ ដល់ព្រះពុទ្ធសាសនកាលកន្លងទៅបាន ១០០ ឆ្នាំ គ្រានោះ ពួកភិក្ខុជាកូនរបស់

អ្នកស្រុកវជ្ជីនាំគ្នាសំដែងវត្ថុដែលខុសចាកធម្មវិន័យ ១០ ប្រការថា ជាធម៌ជាវិន័យ ។

ឯវត្ថុ ១០ ប្រការនោះ គឺ:

១ - កប្បតិ សិង្គិលោណកប្បោ អម្បិលដែលជាក់ទុកក្នុងក្ងាក់ស្នែង ទុកឲ្យកន្ងងរាត្រីហើយយកមកធាន់ជាមួយអាហារបិណ្ឌ-ចាតចាន មិនត្រូវអាបត្តិ ។

២ - កប្បតិ ទ្វង្គុលកប្បោ ព្រះអាទិត្យជ្រៃទៅហើយ ប្រមាណពីរជ្នាប់ ក៏គួរនឹងធាន់របស់ជាយាវកាលិកចាន មិនត្រូវអាបត្តិ ។

៣ - កប្បតិ តាមន្ទរកប្បោ ភិក្ខុមានសេចក្តីគិតថាអញ្ញនឹងចូលទៅកាន់ស្រុក ក៏ត្រូវធាន់អនតិរិត្តភោជនចាន មិនត្រូវអាបត្តិ ។

៤ - កប្បតិ អាវាសកប្បោ ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុសង្ឆនឹងធ្វើសង្ឆកម្មទាំងពួងផ្សេងគ្នាចាន មិនត្រូវអាបត្តិ ។

៥ - កប្បតិ អនុមតិកប្បោ កាលដែលនឹងធ្វើសង្ឆកម្មទាំងពួងមិនចាច់ចាំឲ្យជុំគ្នាទេ ហើមកជល់មុន នឹងធ្វើសង្ឆកម្មមុនបណ្តើរទៅក៏ចាន ឥតទាស់ទ្បើយ ។

៦- **ការ**ប្ដូ**ត** **អ**ាចិ**ណ្ណ**ា**ការ**ម្ម**ា** សេចក្ដីប្រតិបត្តិដ៏ចរិតទំនៀមទំលាប់របស់ខ្លួនជ្រាយ៉ៅ អាចារ្យ ទោះខ្ញុំសក្ដិត្រូវក្ដី សិស្ស-ខ្ញុំសិស្សទាំងពួងត្រូវប្រតិបត្តិតាមបាន គ្មានមានទាស់ ។

៧- **ការ**ប្ដូ**ត** **អ**ម**ជ**ិ**ត**ការ**ម្ម**ា** ទឹកដោះស្រស់ដែលប្រ-ចាកកាពដើមហើយ តែមិនទាន់ក្លាយទៅជាទឹកដូចឡើយ ក៏ខ្ញុំគ្រាកចាកទីអង្ករហើយ ធានទឹកដោះជាអនតិវត្តបាន ។

៨- **ការ**ប្ដូ**ត** **ជ**ណ្ដោ**ក** **ចា**ត្ដ**ុ** **ត**ុ**ណ**ា**ស**ុ**ភ** សុភវ៉ែលគេជាក់ត្រឿងស្រវ៉ែងធ្ងន់ត្រាំជាមួយគ្នាហើយ តែនៅខ្ទ្រាយមិនទាន់ពេញជាទឹកស្រវ៉ែងនៅឡើយ ក៏ខ្ញុំធានបាន ។

៩- **ការ**ប្ដូ**ត** **អ**ន**ស**ន**ំ** **ន**ិ**ស**ី**ធ**ន**ំ** សំពត់ទំនិសីទនៈមិនចាប់ផ្ដើមឲ្យមានជាយ ក៏ត្រូវប្រើបាន មិនមានអាបត្តិឡើយ ។

១០- **ការ**ប្ដូ**ត** **ជ**ា**ត**ិ**ប**ូ**រ**ណ**ំ** ក៏ខ្ញុំគួរទទួលត្រែកអាចំពោះមាសនឹងប្ដាក់បាន មិនត្រូវអាបត្តិឡើយ ។

ព្រះយសត្ថេរ បុត្រកាកណ្ឌកព្រាហ្មណ៍ ចានជ្រាបការប្រព្រឹត្ដ-ដូច្នោះ ក៏សង្ឃតព្រះទ័យ គ្ងាតបងសេង ដកវត្ថុ ១០ ប្រការនោះ ចេញចេញ ទើបនិមន្ដទៅក្នុងវេសាលី ដើម្បីរម្ងាប់អធិករណ៍នោះ ។ សម័យនោះឯង ព្រះសង្ឆទាំងឡាយ ចានសន្ទនាព្រះថេរ ៨ អង្ករ ឲ្យទទួលការនុ: ជាអ្នកពាក្យសំរេចរឿងនោះ ហើយទើបនាំគ្នាទៅកាន់ភ្ជ

ក៏លុះការកម្មក្នុងវេសាលី ប្រជុំគ្នាជាសង្ឃសន្និបាតជំរះវត្ថុ ១០ ប្រការនោះ ហើយវិនិច្ឆ័យសំរេចសេចក្ដីថាជាវត្ថុខុសពាក្យពុទ្ធប្បញ្ញត្តិ នាំឲ្យកើតអាបត្តិ (ទោស) ដល់ភិក្ខុអ្នកប្រព្រឹត្តកន្លង ។ ក្នុងសង្គីតិការៈនេះ ព្រះរេវតត្ថេរ ជាអ្នកបុច្ឆា ព្រះសព្វកាមីជាអ្នកវិសជ្ជនា ព្រមដោយព្រះសង្ឃជាអរហន្ត ចតុប្បដិសម្ភិទាញាណចំនួន ៧០០ អង្គ តាមរបៀបដែលព្រះអរហន្ត ៥០០ អង្គបានធ្វើមកហើយ មានព្រះបាទកាលាសោករាជជាពុទ្ធសាសនូបត្ថម្ភក៍ ធ្វើ ៨ ខែទើបសំរេច ។

តតិយសង្គាយនា

ព្រះមហាថេរទាំងឡាយ បានលើកទុតិយសង្គាយនារួចហើយរំពឹង មើលទៅក្នុងអនាគតឃើញថា ដំណាតទៅខាងមុខ រវាងព្រះពុទ្ធសាសនកាលបាន ២១៨ ឆ្នាំ ព្រះបាទធម្មាសោករាជនឹងទ្រង់ឧប្បត្តិឡើងក្នុងក្រុងបាតលីបុត្ត ហើយបានសោយរាជសម្បត្តិក្នុងសកលជម្ពូទ្វីប ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយនឹងញុំាងលាភសក្ការៈធំឲ្យប្រព្រឹត្តទៅ ម្ល៉ោះហើយពួកនិគ្រន្ថតិរ្ថិយ ដែលមានសេចក្ដីក្រីក្រលំបាក ប្រាថ្នាលាភសក្ការៈ នឹងលបចូលបួសបំបន្លំក្នុងពុទ្ធសាសនមណ្ឌល ហើយយកលទ្ធិរបស់ខ្លួនមកសំដែងអាងថាជាពុទ្ធសាសនា, កាលបើយ៉ាងនេះព្រះពុទ្ធសាសនា ឈ្មោះថាមានមន្ទិលធំកើតឡើង ។

គ្រានោះ ព្រះថេរទាំងឡាយរំពឹងឃើញថាតិស្សមហាព្រហ្ម អាចជំរះមន្ទិលនោះបាន ទើបលោកហោះឆ្ពោះទៅកាន់ទេវលោកអារាធនាតិស្សមហាព្រហ្មឲ្យទទួលភារៈ រួចហើយវិលត្រឡប់មកដាក់ធុរៈឲ្យព្រះសិគ្គវៈនឹងព្រះចន្ទវជ្ជី ដែលមិនបានចូលកាន់សង្ឃសន្និបាតក្នុងតតិយ-សង្គាយនាឲ្យទទួលភារៈសំរេចឧបសម្បទាកិច្ច នឹង បង្រៀន ព្រះបរិយត្តិ-ធម៌ដល់តិស្សមហាព្រហ្ម ដែលនឹងច្យុតមកកើតក្នុងត្រកូលនាងមោគ្គលី-ព្រាហ្មណីក្នុងកាលអនាគត ។

លុះដល់សម័យដែលតិស្សមហាព្រហ្មច្យុតមកកើតក្នុងត្រកូលនាងមោគ្គលីព្រាហ្មណីហើយ ព្រះសិគ្គវត្ថេរជាអ្នកទទួលបំបួស ព្រះចន្ទវជ្ជីជាអ្នកទទួលបង្រៀន ដរាបដល់ព្រះមោគ្គលីបុត្តតិស្សត្ថេរបានជាសង្ឃបាមោក្ខជាប្រធានរបស់សង្ឃក្នុងជំនុំនោះ ៗ ដល់មករជ្ជសម័យនៃព្រះបាទសិរីធម្មាសោករាជ ក៏មានមន្ទិលកើតឡើងក្នុងពុទ្ធសាសនមណ្ឌលដូចសេចក្តីយល់របស់ព្រះសង្គីតិកាចារ្យ ដែលបានពិចារណាឃើញគ្រប់ប្រការ, ព្រះសង្ឃបែកគ្នាទាំនធ្វើឧបោសថកម្មអស់ ៧ វស្សា ព្រះបរម-ក្សត្រាធិរាជប្រាថ្នានឹងជំរះមន្ទិលព្រះពុទ្ធសាសនា ទើបឲ្យយោធាមាត្យអង្កតចាប់ពួកនិគ្រន្ថ ផ្សឹកអស់រលីង ទុកតែព្រះសង្ឃដែលបរិសុទ្ធ ៗ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរជ្រើសរើសយកព្រះអរហន្ត ដែលបានបដិ-សម្ភិទាញាណរំបកធ្លាយក្នុងវិធព្រះត្រៃបិដក បានចំនួន ១.០០០ អង្គ

នាំគ្នាធ្វើសង្គាយនាលើកព្រះពុទ្ធសាសនា ជាគ្រាទី ៣ ក្នុងអសោការាមក្រុងបាតលីបុត្រមហានគរ តាមដំណើរដែលព្រះសង្គីតិកាចារ្យបុរាណបានធ្វើមកហើយ មានព្រះបាទសិរីធម្មាសោកជាសាសនូបត្ថម្ភក៍ អស់កាល ៩ ខែទើបសំរេច ។

ចតុត្ថសង្គាយនា

ព្រះមោគ្គលីបុត្តតិស្សត្ថេរបានធ្វើតតិយសង្គាយនារួចហើយ រំពឹងមើលទៅក្នុងអនាគតឃើញថា ព្រះពុទ្ធសាសនា នឹងទៅប្រតិស្ឋានក្នុងបច្ចន្តប្រទេសទើបចាត់ព្រះអរហន្តខីណាស្រពឲ្យនាំព្រះពុទ្ធសាសនាទៅប្រតិស្ឋានទុកនៅប្រទេសផ្សេងៗ ។ ចំណែកព្រះមហិន្ទត្ថេរបានទទួលថេរបញ្ជាឲ្យទៅប្រកាសព្រះពុទ្ធសាសនានៅនាលង្កាទ្វីប ញុំាងព្រះបាទទេវានម្បិយតិស្សនឹងអ្នកលង្កាឲ្យមានសេចក្តីជ្រះថ្លា ។

គ្រានោះ ព្រះនាងអនុឡាដែលជាជាយារបស់ព្រះមហានាគឧបរាជ ជាព្រះរាជអនុជា មានប្រាថ្នាចង់បព្វជ្ជាជាភិក្ខុនី ។ ព្រះបាទក្រុងលង្កាទ្រង់បញ្ជូនរាជទូតទៅក្រុងបាតលិបុត្ត ជម្ពូទ្វីប ដើម្បីក្រាបទូលព្រះបាទធម្មាសោករាជ សូមអារាធនាព្រះសង្ឃមិត្តាថេរី ព្រះរាជធីតាមកសំរេចកិច្ចឧបសម្បទា ដល់ស្ត្រីជាតិសីហឡ: នឹង សូមអញ្ជើញមែកព្រះមហាពោធិព្រឹក្សមកផង ព្រះអង្គក៏ទ្រង់ព្រះរាជានុញ្ញាតតាម ។

កាលព្រះពុទ្ធសាសនារុងរឿងឡើងហើយ ព្រះចៅទេវានម្បិយតិស្ស ត្រាស់សួរព្រះមហិន្ទត្ថេរថា ព្រះពុទ្ធសាសនាបានឈ្មោះថាប្រតិស្ឋានស៊ប់ក្នុងទីនោះហើយឬនៅ? ព្រះថេរថ្វាយព្រះពរថា ព្រះពុទ្ធសាសនាដែលនឹងបានយាងចុះស៊ប់ស្ងួន លុះតែបានលើកដម្កើងព្រះធម្មវិន័យ ។ ស្ដេចក៏ប្រារព្ធដើម្បីនឹងធ្វើសង្គាយនា ទើបទ្រង់អារាធនាព្រះមហិន្ទត្ថេរជាអ្នកបុច្ឆា ព្រះអរិដ្ឋមហាថេរជាអ្នកវិសជ្ជនា ។ ព្រះសង្ឃស្រុកលង្កាបានស្ដូត្ររៀនចេះចាំព្រះពុទ្ធវចនៈ បែកធ្លុះធ្លាយតគមានសល់ចំពាក់ទាក់ ទើសកាចជាគណបាមោក្ខ រៀនប្រដៅកុលបុត្រក្នុងទីនោះបាន ល្មមសន្និដ្ឋានថា ព្រះពុទ្ធសាសនាមានឫសចុះស៊ប់ក្នុងទីនោះមែន ។

សង្គាយនាគ្រានោះ បានធ្វើនៅក្នុងថូបារាមក្នុងអនុរាធបុរី ដោយគណសង្ឃ ៦៨ ០០០ អង្គ មានព្រះចៅទេវានម្បិយតិស្សជាសាសនូបត្ថម្ភក៍ អស់កាល ១០ ខែ ទើបសំរេច ក្នុងរវាងព្រះពុទ្ធសករាជ ២៣៦ វស្សា ។

បញ្ចមសង្គាយនា

ព្រះបាទទេវានម្បិយតិស្ស ក្សត្រក្រុងលង្កាទ្វីប ទ្រង់មានបុញ្ញានុភាពប្រកបដោយបញ្ញាច្រើនបានបំពេញព្រះរាជកុសលផ្សេងៗ ជាអនេក ហើយស្ដេចទិវង្គតទៅ ។ បន្ទាប់អំពីនោះមក ព្រះបាទឧត្តិយៈ, ព្រះបាទមហាសិវៈ នឹង ព្រះបាទសុរតិស្ស បានសោយរាជ្យជាលំដាប់គ្នាហើយ ទំនុកបម្រុងព្រះពុទ្ធសាសនាតរៀងមក ។

ចំណែកចិត្តកាលមកទាន់ក្រោយ ផ្ទៃក្រៅត្រូលផ្ទាំងទ្រឹបចេះតែទទួលគ្រោះថ្នាក់អំពីបច្ចាមិត្តរឿយៗ រហូតដល់ផ្ទាស់ពីផ្ទៃ ម្ល៉ោះហើយព្រះពុទ្ធសាសនាចេះតែលិចអណ្តែត ។ ទៅតាមផ្ទៃក្រៅត្រដែលជ្រះថ្នាន់ធ្លាក់មិនជ្រះថ្នា ។

ដល់មកសម័យព្រះបាទវជ្ជគាមិនីអភ័យ ឃ្លានកំចាត់បច្ចាមិត្តអស់ហើយ ទ្រង់ឃ្លានសោយពាក្យសិប់ស្ងួនជាក្រៅត្រឯកពាក្យ ទ្រង់ឃ្លានសាងវត្តអភយគិរីប្រគេនព្រះតិស្សត្ថេរ ព្រមទាំងទំនុកបម្រុងដោយចតុប្បច្ច័យបរិបូណ៌ ជាហេតុនាំឲ្យព្រះសង្ឆមហាវិហារកើតសេចក្តីច្រណែនលើកទោសព្រះតិស្សត្ថេរថា ចិបូកចិបាលដោយគ្រហស្ថ ។ ១ណ:ខ្លោះព្រះសង្ឆបែកគ្នាជា ២ ពួក គឺពួកទាន់មហាវិហារ ១ ទាន់ពួកអភយគិរីវិហារ ។

ក្នុងសម័យនោះ ពួកព្រះសង្ឆដែលមានប្ញាញ ឃើញហេតុដែលនាំឲ្យសាបសូន្យព្រះពុទ្ធសាសនា ទើបនាំគ្នាលើកសង្ឆាយនាជាគ្រាទី ៥ គឺ ចារកត្រៃបិដកជាភាសាអក្សរជាក់ក្នុងស្លឹករឹតជាលើកដំបូងដែលប្រើអក្សរជាគ្រឿងកត់ត្រា ព្រះពុទ្ធវចនៈ ។

សង្ឆាយនាលើកនេះ ធ្វើក្នុងមហាវិហារ នាលង្ការទ្វីប មានការកសង្ឆពាក់ពាន់អង្គ មានព្រះពុទ្ធទត្តត្ថេរជាប្រធានជាអ្នកបុច្ឆា ព្រះតិស្សត្ថេរជាអ្នកវិសជ្ជនា មានព្រះបាទវជ្ជគាមិនីអភ័យជាពុទ្ធសាសនូបត្ថម្ភក៍អស់កាល ១ ឆ្នាំទើបសំរេច ។

(មានត)

ជំណឹងពុទ្ធសាសនាក្នុងនានាប្រទេស

ហ្ជូងនិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

រឿងរ៉ាវ ឬ ជំណឹងព្រះពុទ្ធសាសនាដែលមានសេចក្តីផ្សាយក្នុងកាសែតរបស់ប្រទេសនានានោះ នៅក្នុងស្រុកខ្មែរយើងនេះ ពួកពុទ្ធសាសនិកជនមិនសូវចាន់ដឹងពុរាល់ត្នាទេ ឯរឿងរ៉ាវដែលយើងនាំយកមកផ្សាយនេះ ពិតមែនតែមានសេចក្តីផ្សាយក្នុងកាសែតប្រទេសក្រៅយូរក្រែលហើយ ប៉ុន្តែពួកសាសនិកជននៅស្រុកអាយ នៅមិនទាន់ចាន់ជាបរាល់ត្នា ក៏គួរតែនាំយកមកចុះផ្សាយខ្លះដែរ ដូចមានសេចក្តីសារសំពួតទៅនេះ:

សមាគមមហាពោធិ ជាពុទ្ធិកសមាគមយ៉ាងធំ ១ ដែលតាំងមន្ទីរចាត់ការរបស់សមាគមនៅស្រុកកល្កុត្តា ប្រទេសតណ្ឌា, កាលមុនកើតយុទ្ធភ័យទ្បើងក្នុងលោក សមាគមនេះចាន់ចាត់រៃអង្គាសយោសនាប្រាក់កាសអំពីពួកពុទ្ធសាសនិកជនទុទៅក្នុងលោក ដើម្បីយកទៅជួសជុលរចនិយស្ថានយ៉ាងសំខាន់បំផុត ដែលហៅថាមហាវិហារពុទ្ធគយា តាំងនៅក្នុងស្រុកគយា ខែត្រពិហារ ប្រទេសតណ្ឌា ។

ទីតំបន់នេះហើយ ក្នុងសម័យពុទ្ធកាល ហៅថា "ឧរុវេលាសេនានិគម" តាំងនៅក្នុងដែនមគធ: ជាកន្ទែងត្រាស់ដឹងព្រះបរមាភិសេក-

សម្ងាសម្ពោធញ្ញាណរបស់ព្រះបរមសាស្តា ទើបគួរជាទីគ្រាបនមស្សការ នឹងធ្វើសក្ការបូជានៃពួកពុទ្ធបរិសទ្ធ ចាត់ជាសំវេជនីយស្ថានដ៏សំខាន់ ១ ក្នុងសំវេជនីយស្ថានទាំង ៤ អង្ខ្ញើ ។

ព្រះវិហារពុទ្ធគយានេះ អំពីដើមនោះគេសាងជាអង្ក្ត ព្រះស្ពូបសណ្ឋាន ៤ ជ្រុង រៀងស្មើចង្ហើងទៅលើមាន ៨ ជាន់ ។ ក្រោមមានរបៀងព័ទ្ធជុំវិញ ទៅជ្រុងទិសទាំង ៤ មានវិហារមួយ ។ ទៅគ្រប់ទិសទាំង ៤ តែមានទំហំតូច ។ ទៅរមៃរបៀងមានចេតិយតូចរៀងរាយទៅ ។

តាមរឿងព័ត៌ មានសេចក្តីតំណាលថា ព្រះបាទធម្មាសោកពាជ ទ្រង់ឥសាងទុកមកជាពុទ្ធបូជា ក្នុងពុទ្ធសករាជ ២៧៤ ដើម្បីជាទីកត់សំគាល់ផ្ទៃដ ត្រាស់ដឹងនៃ ព្រះពុទ្ធជាម្ចាស់ ។

លុះអំណោះកាលតមកជាវេលាជាង ១០០ ឆ្នាំ ប្រាកដតាមសេចក្តីកត់ហេតុរបស់សមណទូតចិនដែលបានត្រៃចមនមស្សការបូជនីយស្ថានដល់ផ្ទៃដនោះ ថា ព្រះវិហារពុទ្ធគយា គេចោះបង់ចោលមានតែព្រៃដុះទ្ចប ទ្ចុល ជាទីលំនៅនៃ**ស**ត្វព្រៃ លុះអំណោះកាលជាយូរអង្វែងមកទៀត ដល់ពុទ្ធសករាជ ១១៧២ ទើបមានសមណទូតចិនចូលទៅប្រទេសឥណ្ឌាទៀត ដើម្បីនមស្សការបូជនីយស្ថាន នឹងសិក្សាវិជ្ជាចំពោះក្នុងព្រះពុទ្ធសាសនា ឃ្ញានពោលថា ព្រះវិហារពុទ្ធគយានេះ គេឃ្ញានជួសជុល ឃ្ញានស្ពានឡើងវិញហើយ ។

លុះមកដល់ ព.ស. ២៤០៦ ព្រះវិហារពុទ្ធគយា គេឃើញថាមានក្ងួចវាតចាក់ដែកទៅជាច្រើន ទើបពួកពុទ្ធបរិស័ទ្ធ ជាតិកូមាចាត់ការជួសជុលក្នុង ព.ស. ២៤២០ ។ តមកគ្រាយទៀត ព្រះវិហារពុទ្ធ-គយា ក៏ប្រែប្រួលត្រឡប់ទៅជាទីវាលគ្រាមត្រួតត្រារបស់ពួកហិណ្ឌូវិញ ដែលហៅថា ពួកមហន្ត ជាចៅអធិការដែលជាឯកទាងសាសនាហិណ្ឌូ (ព្រាហ្មណ៍) ក្នុង ព.ស. ២៤៣៤ ។ តមកពួកក្រុមជំនុំគណៈជាតិតណ្ហា ចាប្រជុំព្រមព្រៀងគ្នាថា ត្រូវឲ្យពួកពុទ្ធបរិស័ទ្ធមានសិទ្ធិអំណាចបូជាទៅនមស្សការស្ថានទីនោះបាន ហើយពួកក្រុមអភិបាលជាអ្នកចាត់ការការពារទីនោះ ត្រូវមានហិណ្ឌូ ៥ នាក់ ពុទ្ធបរិស័ទ្ធ ៥ នាក់ជាដាច គឺថា ព្រះវិហារពុទ្ធគយា ត្រឡប់ចាមកជាសម្បត្តិរបស់ពួកពុទ្ធសាសនិកជនឡើងវិញទៀត ។

ឯពួកមហន្តជាចៅអធិការទាងហិណ្ឌូ ក៏នាំគ្នាទទឹងតាស់ហើយតវ៉ាថា ព្រះវិហារពុទ្ធគយា គឺជារបស់ហិណ្ឌូ ព្រោះព្រះពុទ្ធជាអម្ចាស់ទុកជាព្រះនារាយន៍ ពួកអ្នកបូជាហិណ្ឌូ តែងថ្វាយចាយបិណ្ឌ (ដុំចាយ) ដល់ព្រះពុទ្ធជាម្ចាស់ ដ៏ជាបុព្វបុរសរបស់ខ្លួនរហូតមក ហើយចានស្នើគោលសំខាន់ៗ ឲ្យក្រុមជំនុំពិនិត្យដូចខ្លះ:

១ - តើវត្ថុនេះកសាងឡើងដោយស្នាដៃពួកហិណ្ឌូ ឬ ពួកពុទ្ធបរិស័ទ្ធ?

២- ព្រះពុទ្ធជាម្ចាស់ស្ថិតនៅកន្លែងអាជ្ញាធរបស់ហិណ្ឌូ ឬ?

៣– ឥឡូវនេះ ពួកហិណ្ឌូ ឬពួកពុទ្ធបរិស័ទ ដែលជាអ្នកគោរពបូជាព្រះពុទ្ធជាម្ចាស់ដោយសេចក្ដីជ្រះថ្លាពិតៗ ?

៤– អំណាចតាមច្បាប់របស់ពួកមហន្ទ និងពួកពុទ្ធបរិស័ទនោះដូចម្ដេច ?

ទុកជាយ៉ាងណាក៏ដោយ ក្រុមជំនុំគណៈជាតិឥណ្ឌា បានជំនុំព្រមឲ្យសេចក្ដីយុត្តិធម៌ដល់ពួកពុទ្ធបរិស័ទយ៉ាងល្មមសមគួរ ព្រោះតាមធម្មតានោះ ស្រុកម៉ក្កៈជាស្ថានសំខាន់របស់ពួកមូស្លីម យ៉ាងណា ? ស្រុកអយោធ្យាជាស្ថានសំខាន់របស់ពួកហិណ្ឌូ យ៉ាងណា ? ស្រុកសេរូសាលែមជាស្ថានសំខាន់របស់ពួកគ្រិស្ដាំង យ៉ាងណា ? ព្រះវិហារពុទ្ធគយា ក៏ត្រូវជាស្ថានដ៏សំខាន់របស់ពួកពុទ្ធបរិស័ទយ៉ាងនោះដែរ ។

ក្នុងការសុំសិទ្ធិអំណាចអំពីរដ្ឋបាលឥណ្ឌានោះ ពុទ្ធិកសមាគមមហាពោធិ បានទទួលសេចក្ដីយល់ព្រមនិងសេចក្ដីត្រេកអរអនុមោទនាអំពីមនុស្សសំខាន់ៗ ទាំងជាតិឥណ្ឌានិងជនជាតិទេប ដូចមានបរិយាយសង្ខេប ៗ តទៅនេះ :

១– មហាត្មគន្ធី ពោលថា :

“ មិនបាច់ងឿងឆ្ងល់យ៉ាងណាទៀតឡើយ វត្តពុទ្ធគយាគួរបានមកជាកម្មសិទ្ធិរបស់ពួកពុទ្ធសាសនិកជន . . . ខ្ញុំឯងក៏ស្ម័គ្រចិត្តជួយបង់ឲ្យពួកពុទ្ធសាសនិកជនបានវត្តនេះ ត្រឡប់មកវិញដែរ . . . ”

២ – ដុកទ័ រ ពាំ ន្ធ្ងនាថ តាគោ ពោលថា : "ខ្ញុំដឹងច្បាស់ក្នុងចិត្ត ថា ពួកអ្នកកាន់សាសនាហិណ្ឌូទាំងអស់ ដែលជាអ្នកគ្រាប់ខ្ជាប់ខ្ជួនកាន់ស្ថាន-ធម្មរបស់ខ្លួន គោងយល់ព្រម (ដែលចែកសិទ្ធិកាន់វត្ថុពុទ្ធគយា) ឲ្យ ពួកពុទ្ធបរិស្ទ ១ ១ ព្រោះមិនគួរបណ្ដោយឲ្យវត្ថុដែលគេបានកសាងឡើង នៅកន្លែងត្រាស់ដឹងរបស់ព្រះពុទ្ធ ធ្លាក់ទៅនៅក្រោមអំណាចអ្នកកាន់ សាសនាដទៃឡើយ ហើយជាពួកមិនបានសិក្សាវិជ្ជាពុទ្ធសាសនាយ៉ាងមុតមាំ ទាំងមិនមានសេចក្ដីគោរពយ៉ាងមុតមាំចំពោះពុទ្ធសាសនាផង ទាំងមិនបានធ្វើពុទ្ធបូជាតាមប្រពៃណីព្រះពុទ្ធសាសនាផង . . . "

៣ – លោកទាសពន្ធ ចានធ្វើយសេចក្ដីក្ងោះសាជ្ញាកាសតមួយ ដែលសុំសួរពីសេចក្ដីយល់ឃើញរឿងវត្ថុពុទ្ធគយាថា : "ខ្ញុំមានសេចក្ដីយល់ឃើញតែមួយផ្លូវថា វត្ថុពុទ្ធគយាជាសម្បត្តិរបស់ពុទ្ធសាសនិកជន ខ្ញុំមានបំណងចង់សុំឲ្យពួកហិណ្ឌូ លើកប្រគល់វត្ថុនេះឲ្យទៅពួកពុទ្ធសា-សនិកជនគ្រប់គ្រង ឬដោយហេតុទៅ កុំទទួលការធ្វើសក្ការៈបូជា តាមបែបប្រពៃណីរបស់គេឡើយ "

៤ – ស្ទ្រីអ៊ីតវ៉ាន អ៊ីរ៉ានោលត៍(១) ពោលថា : "ខ្ញុំធ្លាប់ចានប្ដឹងដល់រដ្ឋបាលតំណាងនៃប្រមុខជនជាតិហិណ្ឌូ អំពីការហ្ចុះបង់ចោលស្ថានទីដ៏មានកិត្តិយស ក្នុងប្រវត្តិនៃបរមត្ថវិជ្ជារបស់ជនជាតិតំណាងទាំងឡាយ

• ហេតុនេះជាជនជាតិអង្គ្លេសមានសេចក្ដីគ្រិះថ្នាក់ក្នុងព្រះពុទ្ធសាសនា ។

តាំងអំពីនោះមកខ្ញុំក៏តាំងចិត្តចាំមើលថា កាលណាទើបវត្តនឹងឧបចារៈរបស់វត្ត បានមកនៅក្នុងការគ្រប់គ្រងរបស់ពួកពុទ្ធបរិស័ទវិញ . . . "

៥ — ម៉ាដាមអាលេក្សង់ដ្រា ដាវិតនីល[១] ពោលថា : " ចុះនៅមានបុគ្គលណាមួយសោត អាចប្រើមនោគតិៈរៀបចំគោលនៃវិរិយៈនឹងការជឿខ្លួនឯងឲ្យខ្ពស់ជាង ឬឲ្យជាប់ចិត្តជាងរបៀបបែបបទរបស់ព្រះសិទ្ធាថ៌គោតមៈបរមសាស្តា ដែលទ្រង់បានគិតសម្រេចនៅក្រោមដើមពោធិព្រឹក្សនៅតំបន់ពុទ្ធគយានេះ ។

អ្នកគោរពព្រះអង្គនិងពួកសាវកព្រះអង្គ តែងមានសេចក្តីងឿងឆ្ងល់មិនបាត់ ដែលឃើញអ្នកកាន់សាសនាឯទៀតមកមានអំណាចគ្រប់គ្រងទីកន្លែងដែលខ្លួនប្រកាន់ជឿជាក់ថា ជាតំបន់ដែលព្រះសាស្តារបស់ខ្លួនបានត្រាស់ដឹងសម្រេចផលដ៏ឧត្តម កំបាត់បង់ការជឿប្រកាន់ជាគជតានឹងជឿទោះបីសាចបានជាប់ស្រឡះបាកសន្តានរបស់ព្រះអង្គ ។ល។

៦ — បណ្ឌិត រិធសេខរៈ កដ្ឋាចារ្យ ជាចាងហ្វាងវិស្វការតិមហាវិទ្យាល័យស្រុកពលបុរៈ[២] ពោលថា:" សុំឲ្យពួកយើងជាតិហិណ្ឌូទាំងពួង បូរនាំគ្នាត្រិះរិះពិនិត្យពាក្យសួរអំពីរឿងវត្តពុទ្ធគយា ដោយគំនិតដ៏

---

១ ជាស្ត្រីជាតិបារាំងសែស ជាអ្នកត្រាចស្វែងរកចំណេះចេះដឹងនៅអាស៊ីខាងកើត ធ្លាប់ដើរទៅប្រទេសចិន ឥណ្ឌា ទីបេ ។

២ មហាវិទ្យាល័យ នៅក្រោមឧបត្ថម្ភរបស់ពេទ្យនាថ តាគោរ ជាទីទទួលអ្នកសិក្សាមិនរើសជាតិរើសសាសនាឡើយ ។

ស្អាតផូរផង់ផុះឡើងត្រង់កណ្ដាលបេះដូងរបស់យើង កុំបីមានចិត្តប្រកបដោយអាឃាតព្យាបាទឡើយ គង់តែនឹងមើលឃើញសេចក្ដីពិតថាមានតែពួកពុទ្ធសាសនិកជនប៉ុណ្ណោះទេ ដែលសមគួរជាងពួកយើង ក្នុងការថែរក្សាគ្រប់គ្រងបូជនីយស្ថាននៅតំបន់នេះ" ។

៧– លោក ដ. ន. សេន (D N Sen) ចាងហ្វាងវិទ្យាល័យពិហារណាស្យូណាល់ នៅស្រុកបតនៈ(១)

លោកនេះថ្លែងយោបល់យល់ឃើញវែងឆ្ងាយ តែបើរួមសេចក្ដីខ្លី ៗ ទៅថា "រឿងអ្នកកសាងពុទ្ធគយាក្ដី អ្នករក្សាគ្រប់គ្រងក្ដី មិនមែនជារឿងធម្មតាដែលតាមតែនិយាយឲ្យផុតពីមាត់ទៅបានទេ ពោធិមណ្ឌលស្ថាន (កន្លែងព្រះមហាបុរសបានត្រាស់សម្មាសម្ពោធិញ្ញាណ) ជាតំបន់សំខាន់បំផុតក្នុងប្រវត្តិសាស្ត្រ ជាកំណើតនៃអារ្យធម៌របស់ឥណ្ឌា) ល្មមបើកឡើងអ្នកបាន ទាំងអ្នកកាន់ពុទ្ធសាសនា ទាំងមិនមែនអ្នកកាន់ពុទ្ធសាសនា ដូច្នេះពួកហិណ្ឌូសាសនិកៈនិងពួកពុទ្ធសាសនិកៈនៅវាទគ្នាធ្វើអ្វី ព្រោះខ្លួនខ្ញុំឯងក៏ធ្លាប់បានឃើញទេវរូបជាចំនួនច្រើនខាងសាសនាហិណ្ឌូនិងបូជនីយវត្ថុឯទៀត ៗ មាននៅក្នុងរោងទុឃោសចវិហារ ក្នុងវត្តកូឡុម្បូ កោះលង្កា សឲ្យឃើញថា ពួកពុទ្ធសាសនិកៈ ក៏មានសេចក្ដីជ្រះថ្លាក្នុង

១ អំពីដើមហៅថាក្រុងបាតលីបុត្រ ក្នុងសម័យព្រះបាទធម្មាសោក

សាសនាព្រាហ្មណ៍ដែរ ដូច្នេះសូមឲ្យពួកបណ្ឌិតអនុញ្ញាតឲ្យពួកអ្នកកាន់ព្រះពុទ្ធសាសនា បានចាប់រក្សាបូជនីយស្ថានដ៏បរិសុទ្ធរបស់គេផងចុះ ។

ក្រៅអំពីបុគ្គលសំខាន់ៗ ដែលបានបញ្ចេញឈ្មោះមកខាងលើនេះ នៅមានមនុស្សសំខាន់ៗឯទៀតជាច្រើន ដែលបានយល់ឃើញដល់ចិត្តគំនិតដ៏ល្អបរិសុទ្ធរបស់ពួកពុទ្ធសាសនិកជន តែយើងមិនចាំបាច់នាំមកថ្លែងក្នុងទីនេះដោយសព្វគ្រប់ទេ ។

ហេតុដែលយើងនាំយករឿងរ៉ាវមហាវិហារពុទ្ធគយាមកសំដែងនេះ ដើម្បីបង្ហាញឲ្យឃើញដម្លៃរបស់ព្រះពុទ្ធសាសនាប៉ុណ្ណោះ ព្រោះព្រះពុទ្ធសាសនារបស់យើង ជាសាសនាពិតបរិសុទ្ធមិនមានក្នុងក្រៅ ជាសាសនាត្រង់ ត្រូវតាមគន្លងវិទ្យាសាស្ត្រ ទើបជាហេតុឲ្យជនជាតិដទៃ កាន់សាសនាដទៃ ក៏គោរពទទួលរ៉ាប់រងពុទ្ធសាសនារបស់យើងនេះដែរ ។

មួយវិញទៀត ជនជាតិឥណ្ឌាក្នុងសម័យសព្វថ្ងៃនេះ គេច្រើនតែកាន់លទ្ធិសាសនាព្រាហ្មណ៍ និងសាសនាមោហាម័ទ តែមានពួកអ្នកកាន់លទ្ធិសាសនាទាំងពីរនេះ ខ្លះបែរទៅមានចិត្តឈឺឆ្អាលនឹងបង់ជួយឲ្យបូជនីយស្ថានសំខាន់ របស់ព្រះពុទ្ធសាសនាធ្លាក់មកនៅក្នុងការគ្រប់គ្រងរក្សារបស់ពួកពុទ្ធសាសនិកជនវិញ នេះក៏សឲ្យឃើញថា ព្រះពុទ្ធ-សាសនាជាសាសនាផ្សេងដ៏បរិសុទ្ធ ជាពន្លឺនៃដួងវិញ្ញាណរបស់មនុស្សលោកបានពិតប្រាកដមែន ។

តាមដោយពិតនោះ ពុទ្ធសាសនិកជនទាំងឡាយ ដែលបានប្រតល់
កាយថ្វាយខ្ជូនជល់ព្រះរតនៈត្រៃហើយ ទាំងបានសិក្សាចំណេះវិជ្ជាក្នុង
ព្រះពុទ្ធសាសនា បានចេះដឹងជ្រៅជ្រះហើយ រមែងមានបីតីវីកវាយក្សេម
ក្សាន្តក្នុងចិត្ត មិនដែលកើតចិត្តក្តៅក្រហាយស្តាយក្រោយ ពីព្រោះតែ
ប្រតិបត្តិតាមគន្ធងច្បាប់របស់ព្រះពុទ្ធសាសនានេះឡើយ ហេតុនេះហើយ
បានជាពុទ្ធសាសនិកៈ ដែលចេះដឹងពិតៗ មិនដែលងាកចិត្តលះបង់ចោល
ព្រះពុទ្ធសាសនា ហើយទៅកាន់លទ្ធិសាសនាជទៃ ដោយសេចក្តី
ជ្រះថ្លាពិតៗ នោះស្ទើរតែមិនមានសោះឡើយ ។

ស្រុកខ្មែរ - កម្ពុជា ជាដែនមានភ័ព្វសំណាងធំ ដែលបានគោរព
លទ្ធិពុទ្ធសាសនាដ៏បរិសុទ្ធ តាំងអំពីបុព្វបុរសរហូតមកដល់សម័យនេះ
ហេតុនេះ សូមពុទ្ធសាសនិកជនទេមរជាតិទាំងឡាយ នាំគ្នាសិក្សានឹងប្រ-
តិបត្តិតាមព្រះពុទ្ធោវាទ នឹងនាំគ្នាជ្ជួយទំនុកបម្រុងព្រះពុទ្ធសាសនា ឲ្យកាន់
តែបំរើនរុងរឿងឡើងជាភ័យ្យោភាពតទៅអនាគតកាលហោង ។

ចប់តែបុំណ្ណោះ

កែពាក្យខុសក្នុងកម្ពុជសុរិយា

ឆ្នាំ ១៩៤៩ លេខ ១៦

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
និយាយប្រាជ្ញព្រោងអ្ហិតពូកែ	និយាយប្រាជ្ញព្រោងអ្ហតពូកែ	៨៩២	៣
ឧរ្ទ៉ាបជាត្រូបច្ចុប្ឈន្ន	ឧរ្ទ៉ាបជាត្រូបច្ចុប្ឈន្ន	៨៩៣	៨
ហេកពូកឡល់ឡើយមើលឲ្យជ្រិះ	ហេសពូកឡល់ឡើយមើលឲ្យជ្រិះ	៨៩៨	២
ត្រាប់មាន់ប្រាជ្ញស្ពីកាន់សច្ច	ត្រាប់មាន់ប្រាជ្ញស្ពីកាន់ឡៃងគាប់	៨៩១	១១